

- វីរិយ៉ា! បើមានទេពច្យុតចុះមក មានប្រាថ្នាអ្វីទៅ? (វិមន្ត)
- ខ្ញុំចង់ឱ្យខ្លួនឯងក្លាយជាស្ត្រីដ៏ជោគជ័យក្នុងមុខជំនួញ។ (វីរិយ៉ា)
- អស្ចារ្យម្ល៉េះលោកស្រី! រំអ្ហួយអ៊ីចឹងចង់ធ្វើស្ត្រីជោគជ័យស្អីទេ។ (វីណា)
- ឯងចាំតែមើលទៅ! មិនដឹងយូរប៉ុនណាទេ តែខ្ញុំនឹងប្រើពេលមួយជីវិតនេះសម្រេចបំណងមួយនេះ។ (វីរិយ៉ា)

វគ្គ១

# បំណងប្រាថ្នានិងការតាំងចិត្ត

នៅក្នុងបន្ទប់ការិយាល័យធំមួយ ស្ត្រីវ័យប្រហែល៣២ឆ្នាំម្នាក់គ្រងសម្លៀកបំពាក់ហាំហួនជាម្ចាស់បន្ទប់នេះ នាងអង្គុយសញ្ជប់សញ្ជឹងសម្លឹងរូបថតចាស់មួយសន្លឹករម្លឹកដល់អតីតកាលមួយ...

- រីណា! មកខាងនេះ! ឱ្យលឿន ជួយគ្នាបន្តិច! គ្នាមិនហ៊ានទេ ខ្លាចណាស់ ហាសហា...។

សំឡេងសើចនិងស្រែកដោយភាពរីករាយរបស់វីរិយ៉ា។ រីណាក្រោយឮសំឡេងរបស់មិត្តស្រែកហៅ ស្រែកឆ្លើយទាំងរត់មកផង៖

- ស្អីទេ វីរិយ៉ា! បើខ្លាចខំលេងធ្វើអ្វី? គ្រាន់តែអុជកាំជ្រួចសោះក៏ខ្លាចដែរ!

វីរិយ៉ាសើចកាច់កមិនតប រីណាស្រែកហៅមិត្តម្នាក់ទៀត

មកជួយៈ

- វិមន្ត! អុជមិនឆេះទេ មកជួយផងមើល!

វីរិយ៉ាសើចផង តឿនវិមន្តដែលកំពុងដើរមកផង "លឿនៗ!" វិមន្តដើរមកជាមួយនឹងកាមេរ៉ាបន្តោងនៅនឹងកបង្ហាញភាពសង្ហាគួរឱ្យទាក់ទាញ។

- ស្រីៗពីរនាក់នេះ គ្រាន់តែកាំជ្រួចក៏មិនចេះលេងដែរ!

វិមន្តអង្អែលក្បាលវីរិយ៉ា យកកាំជ្រួចពីដៃវីណាមកអុជៈ

- ឆេះហើយ! ឆេះហើយ! (សំឡេងសើចកក្អឹករបស់វីរិយ៉ា)

- លើកឱ្យខ្ពស់ទៅវិមន្ត។ (វីណាបង្គាប់)

កាំជ្រួចហោះខ្ពស់បែកផ្កាភ្លើងភ្លឺពេញផ្ទៃមេឃ វីរិយ៉ាលោតផងទះដៃផងសម្ដែងភាពរីករាយដូចកូនក្មេង។ កែវភ្នែកមួយគូជៀងតាមមើលស្នាមញញឹមរបស់នាងដោយមិនចាប់អារម្មណ៍ថាមានភ្នែកមួយគូទៀតកំពុងតែសម្លឹងមើលខ្លួនដូចគ្នា។

- អស់ហើយ! ឯណា? អុជមួយដើមទៀតទៅ សប្បាយណាស់!

វីរិយ៉ានិយាយទៅ វិមន្តបានត្រឹមតែញញឹមៈ

- មានឯណាទៀត! អស់ហើយវីរិយ៉ា តស់យើង! ទៅដើរ

លេងតាមផ្ទះវិញទៅ! (រីណាឆ្លើយជំនួស)

វីរិយ៉ារត់ប្រុយទៅមុនគេ នាងស្រែកបន្ទឿនមិត្តទាំងពីរះ

- ឱ្យលឿនឡើង! នៅសាសងគ្នាហ្នឹងហើយពីរនាក់ហ្នឹង! ហាសហា!

រីណាធ្វើមុខអឹមអៀនក្រោយឮពាក្យបង្អាប់របស់វីរិយ៉ា វិមន្តតឿនរីណាះ

- តស់រីណា! លឿនបន្តិចទៅ មើលទៅវីរិយ៉ាសប្បាយដល់ហើយ! នាងចូលចិត្តសមុទ្រណាស់ មកលើកណាមុខរីករហូតហ្នឹង!

- រីណាស្គាល់វីរិយ៉ាច្បាស់ណាស់ហ្ន៎!

- មិនស្គាល់ម៉េច បើជាមិត្តថ្លើមមួយហើយហ្នឹង! សួរដូចមិនដឹង! (រីណាតបទាំងធ្វើមុខភ្ញាញ់)

- ក្រែងមានអ្នកណាដែលរីណាស្និទ្ធស្នាលជាងវីរិយ៉ាទៀតណា។

- គ្មានទេ! វីរិយ៉ាញ៉ិកញ៉ក់បន្តិចតែចិត្តល្អ គ្មានមិត្តឯណាប្រៀបនឹងនាងបានទេ វិមន្តឃើញហើយតើ!

- ដឹងហើយ! តែខ្ញុំចង់សំដៅអ្វីផ្សេងៗ។ (វិមន្តផ្លែសម្តីបែប

ខិល)

- យី! វិមន្តចង់និយាយពីអ្វី ខ្ញុំអត់យល់? (រីណាបង្ហាញទឹកមុខឆ្ងល់)

- មិនដែលឃើញរីណានិយាយពីម្ចាស់បេះដូងឱ្យខ្ញុំបានដឹងសោះ ជួបពេលណាអ៊ូតែរីយ៉ាធ្វើបាបរហូតហ្នឹង រីណាបែបអៀនដូចមានអ្វីចង់ប្រាប់ទៅវិមន្ត ស្រាប់តែរីយ៉ាស្រែកទាំងភ្លាត់ "ជួយផង! ខ្ញុំគ្រេចជើងហើយ" នាងអង្គុយរមួលក្រពើនៅមាត់ធ្នេរធ្វើមុខយ៉ាងកម្សត់ មិនបានឃើញមុខអៀនរបស់រីណាទេ វិមន្តស្ទុះរត់យ៉ាងលឿនតាមម្ចាស់សំឡេង៖

- រីយ៉ាយ៉ាងម៉េចហើយ? ក្រោកបានទេ? (វិមន្ត)

- រត់ពេកអ៊ីចឹងហើយ អ្នកនាង!

សំឡេងត្រហេបត្រហបរបស់រីណាទើបរត់មកដល់តាមក្រោយ រីយ៉ាសើចទាំងមុខឈឺ នាងអង្អែលជើងថ្នមៗ៖

- មិនកើតទេ ធ្វើម៉េចទៅ? (រីណា)

- តស់! ខ្ញុំអៀវទៅវិញ យ៉ាប់ណាស់ អ្នកនាងរីយ៉ាគួរតែហៅថាកូនស្វាវិញទៅ!

រីយ៉ាធ្វើមុខអៀនៗឱបកកំលោះវិមន្ត ព្រោះមិនអាចគេច

មិនទទួលការសុំជួយនេះបានទេ។ តាមឆ្នេរសមុទ្រដែលខ្យល់បក់ត្រសៀក រលកបោកច្រាំងគេឃើញវិមន្តបន្តោងកាម៉េរ៉ានៅនឹងក អៀវវីរីយ៉ាដើរតាមឆ្នេរមានរីណានៅក្បែរជាអ្នកកាន់ស្បែកជើងឱ្យមិត្ត។ រូបភាពដ៏កម្រនេះត្រូវបាន Bryant ជាប្រធានផ្នែករបស់ពួកគេថតយកបាន។ Bryant ជាកំលោះជនជាតិខ្មែរកាត់បារាំងដែលមានកុងត្រាមកធ្វើការនៅក្រុមហ៊ុននេះតែ៣ឆ្នាំគត់។

- ខ្ញុំធុនសឹងស្លាប់ មកថតដូចជាទិដ្ឋភាពល្អណាស់អ៊ីចឹង Bryant។ (វិមន្តនិយាយដោយរអ៊ូ)

ដៃមួយឱបក ដៃមួយទះថ្ងាសកំលោះយើង។

- ប្រុសស្អីអ៊ីចេះ អៀវស្រីតូចប៉ុនខ្ញុំហ្នឹងថាធុនទៅកើត! (វីរីយ៉ា)

- មែនហើយ! សមតែត្រូវអ៊ីចឹងទៅវិមន្តឯង! បានអៀវស្រីស្អាតហើយនៅរអ៊ូទៀត។

- ចុះខ្ញុំអត់ស្អាតទេឬ Bryant ទើបបានមកកាន់ស្បែកជើងឱ្យគេអ៊ីចឹង? (រីណា)

- ឯងស្អាតណាស់  ហើយជាពួកម៉ាកល្អទៀត! (វីរិយ៉ា និយាយលួងសម្លាញ់)

- សប្បាយណាស់ពួកយើង ត្រឡប់ទៅវិញត្រូវខំធ្វើការ បញ្ចេញស្នាដៃឱ្យគេស្គាល់សមត្ថភាពការងាររបស់ក្រុមពួកយើង។ (Bryant រម្លឹកកូនចៅ)

- ធ្វើមិនកើតទេលោកប្រធាន! ជើងខ្ញុំឈឺហើយ! នេះមិនសួរមួយម៉ាត់ក៏រម្លឹកពីការងារទៀតហើយ។ (វីរិយ៉ារំអួយដាក់ប្រធានក្រុម)

- មិនបាច់សួរក៏ដឹងថារម្ងួលក្រពើដែរ បើរពឹសដូចវីរិយ៉ាទៅហើយនោះ គ្មានរឿងអ្វីទើបចម្លែក។ (Bryant)

វីណានិងវិមន្តសើចកក្អឹកឌឺដងឱ្យវីរិយ៉ា នាងតូចមិនសុខចិត្តញ៉ឹងត្រចៀកវិមន្តយ៉ាងខ្លាំង៖

- ហ្នឹងណា! សើចទៀតទៅ! (វីរិយ៉ាគំរាមទៅវិមន្ត)

- អ៊ូយៗ! យី! ចុះវីណាក៏សើចដែរតើ ម៉េចបានត្រូវតែខ្ញុំ? (វិមន្ត)

- ទៅធ្វើអ្វីវីណាបានបើខ្ញុំនៅលើខ្នងវិមន្តឯងហ្នឹង! (វីរិយ៉ា)

- ថាធូន់តែមាត់ តែឈឺរអៀវយូរហើយមិនព្រមដាក់ចុះសោះ។ (Bryant លែបខាយដាក់វិមន្ត)

- ចង់ចំណេញណាស់វិមន្ត! (រីណាបន្ទរ)

វីរិយ៉ាភ្ញាក់ខ្លួនអឹមអៀនបន្តិច តែមិនឃើញវិមន្តចង់ដាក់នាងចុះសោះ៖

- ម៉េចវីរិយ៉ា ចង់ឱ្យខ្ញុំអៀវដល់ពេលណាទៀត? ខ្ញុំធ្វើសុភាពបុរសយូរហើយណា។ (វិមន្តបញ្ជើដាក់វីរិយ៉ាយក្សួចខ្លួន)

- អុញ! យីវិមន្តនេះ! ដាក់ខ្ញុំចុះភ្លាម។ (វីរិយ៉ានិយាយទាំងខឹងផងអៀនផង)

Bryant និងរីណានាំគ្នាសើចនឹងគេទាំងពីរ វិមន្តដើរពីរបីជំហានដាក់វីរិយ៉ាអង្គុយនៅលើប៉ោអ៊ីជិតហ្នឹង។

- ម៉ោះ!ខ្ញុំមើលជើងឱ្យ។ (Bryant និយាយទាំងចាប់ប្របាច់ជើងវីរិយ៉ាថ្នមៗរកសរសៃគ្រេច)

- អ៊ូយ! អ៊ូយ! (វីរិយ៉ាស្រែកតិចៗដោយខ្លាចឈឺ)

- បាត់ហើយ! កុំរំអួយពេក! (Bryant)

- មែនហើយ! រំអួយណាស់យើងហ្នឹង! (រីណាបន្ទរ)

វិមន្តសើចចំអក វីរិយ៉ាទះស្មាគេមួយដៃ៖

- អ៊ូយ! វៃខ្ញុំទៀតហើយ! (វិមន្តស្រែក)

- រអ៊ួយណាស់យើងហ្នឹង! (វីរិយ៉ាឌី)

វីណានិង Bryant សើចហួសចិត្តនឹងកាយវិការគួរឱ្យក្នាញ់របស់វីរិយ៉ា។

- តស់យើងទៅសម្រាកវិញទៅយប់ហើយ។ (Bryant)

- អត់ទេ! អត់ទេ! ខ្ញុំចង់នៅទីនេះយប់នេះ! ខ្ញុំចង់មើលទេពច្យុតធ្លាក់។ (វីរិយ៉ាតវ៉ា)

- អ៊ីចឹងនៅចុះ! ខ្ញុំទៅមុនហើយ ថ្ងៃនេះលេងពេញមួយថ្ងៃហើយនៅមិនហត់សោះស្រីតូច ធ្វើការក៏សកម្ម លេងក៏សកម្មដែរ! (Bryant និយាយទាំងអង្អែលក្បាលវីរិយ៉ា)

- ហេតុអ្វីមិននៅលេងជាមួយគ្នាបន្តិចសិនទៅ Bryant? (វីណា)

- មិននៅទេ ខ្លាចត្រូវនាងតូចនេះឃាត់នៅអង្គុយដល់ភ្លឺណាស់ តែយប់នេះគ្មានទេពច្យុតនោះទេ! (Bryant ឆ្លៀតឌឺឱ្យវីរិយ៉ា)

- រាត្រីសួស្តី Bryant! ស្អែកជួបគ្នា! (វិមន្ត)

- រាត្រីសួស្តីទាំងអស់គ្នា! (និយាយហើយលោកប្រធានរបស់ពួកគេក៏ដើរទៅបាត់)

បីនាក់ម៉ង់ៗអង្គុយមាត់ធ្នេរចាំមើលទេពច្យុតដោយវិមន្ត នៅកណ្តាលៈ

- វិរិយ៉ា! បើមានទេពច្យុតចុះមក មានប្រាថ្នាអ្វីទៅ?(វិមន្ត)

- ខ្ញុំចង់ឱ្យខ្លួនឯងក្លាយជាស្រ្តីដ៏ជោគជ័យក្នុងមុខជំនួញ។ (វិរិយ៉ា)

- អស្ចារ្យម្ល៉េះលោកស្រី! រអ្នែយអ៊ីចឹងចង់ធ្វើស្រ្តីជោគជ័យស្អីទេ។ (វីណា)

- ឯងចាំតែមើលទៅ! មិនដឹងយូរប៉ុនណាទេ តែខ្ញុំនឹងប្រើពេលមួយជីវិតនេះសម្រេចបំណងមួយនេះ។ (វិរិយ៉ា)

- បានហើយ! បានហើយ! អ្នកនាងពូកែ មើលទៅមនុស្សប្រុសធម្មតាស្រលាញ់វិរិយ៉ាមិនបានទេ។ (វិមន្ត)

- ទាល់តែខ្លាទើបស្រលាញ់អ្នកនាងហ្នឹងបាន! (វីណា)

- កុំថាឱ្យខ្ញុំ! ចុះឯងនោះវីណា? ឯងចង់ប្រាថ្នាអ្វី?(វិរិយ៉ា)

- មែនហើយ! វីណាប្រាថ្នាអ្វីដែរ? (វិមន្ត)

- គ្រាន់តែចង់បានគ្រួសារដ៏មានសុភមង្គលមួយជាមួយមនុស្សដែលខ្ញុំស្រលាញ់។ (វីណា)

- អ៎! អ្នកនាង! អីក៏លន្លង់លន្លោចម្ល៉េះ? (វីរិយ៉ា)

- ចុះវិមន្តវិញ! ចង់ប្រាថ្នាបានអ្វីដែរ? (វីណា)

- ខ្ញុំដូចជាមិនជឿរឿងហ្នឹងសោះ។ (វិមន្ត)

- យី វិមន្តនេះ! អាចសុំបានមែនណ៎ា! ជឿខ្ញុំទៅ! ហើយមិនមែនចេះតែមាននិស្ស័យបានឃើញនោះទេ! (វីរិយ៉ា)

- ប្រាប់មកចង់ប្រាថ្នាអ្វី! កុំចង់លាក់ណា! (វីណា)

- យី! ក្រមុំទាំងពីរនេះ ម៉េចបានព្រួតគ្នាធ្វើបាបខ្ញុំអ៊ីចឹង? (វិមន្ត)

- វិមន្តប្រាប់មក! (វីណា)

- ខ្ញុំចង់បានបេះដូងរបស់មនុស្សស្រីម្នាក់។ (វិមន្ត)

- អីយ៉ា...! អ្នកណាគេ? ប្រាប់ភ្លាម! (វីរិយ៉ា)

- មិនប្រាប់ទេ! ចង់ដឹងរឿងសម្ងាត់គេអ៊ីចឹង? (វិមន្ត)

- ប្រាប់មកចាំគេជួយធ្វើមេអណ្ដើកឱ្យ។ (វីណា)

- ឱ្យវីណាជួយទៅខ្ញុំមិនជួយទេ ខ្លាចគេចាប់ស្មោរហាសហា។ (វីរិយ៉ា)

- វីរិយ៉ាឯងហ្នឹងក៏ស្មោរបានដែរ? បើមហិច្ឆតាធំម្លឹងៗ។ (វិមន្ត)

- អ៊ីចឹងទៅស្មោរវីណាទៅ។ (វីរិយ៉ា)

- ស្អីគេហ្នឹងពីរនាក់នេះ។ (រីណាបែបអៀន)

អស់ពីមួយរឿងចូលមួយរឿងអ្នកទាំងបីដូចមិនអស់រឿងនិយាយសោះ ស្ងាត់ៗបាត់សំឡេងវីរិយ៉ាកំពុងគេងកើយស្មាវិមន្ត។

- យី! យ៉ាងម៉េចនេះស្រីតូច! ថាមកចាំមើលទេពច្យុតនោះឬ?

- ហ្អេ៎! មើលគេ ចេះមកគេងអ៊ីចឹងកើត! វីរិយ៉ាក្រោកឡើង!

វីរិយ៉ាកាន់តែទន់គេងកើយលើដើមទ្រូងកក់ក្តៅរបស់កំលោះវិមន្តៈ

- តស់លើកនាងទៅគេងលើប៉ោអ៊ីនោះទៅវិមន្ត។

- ចាំខ្ញុំបីនាងទៅ!

- តែងតែដូចក្មេងអ៊ីចឹងវីរិយ៉ា!

- មិនអីទេ រីណាអង្គុយនៅហ្នឹងចុះ!

វិមន្តលើកវីរិយ៉ាត្រកងដើរសំដៅទៅប៉ោអ៊ីខាងមុខរោងនាយទាញកន្សែងដែលវីរិយ៉ាបង់ក យកមកដណ្តប់កាយនាង ដៃមួយគូស្រវាតោងកវិមន្តនិយាយទាំងបិទភ្នែកៈ

- យប់ហ្នឹងដឹងតែមានទេពច្យុតចុះហើយ ជួយប្រាថ្នាឱ្យខ្ញុំផងណា។

- បាទ! ដឹងហើយ!ដឹងហើយ! នឹងទុកបំណងប្រាថ្នាខ្ញុំសិនហើយយកឱកាសនេះប្រាថ្នាឱ្យស្រីតូចឯង ឱ្យសមបំណងតែម្ដងហ្ន៎។

វិមន្តតបទាំងញញឹមនិងអង្អែលក្បាលនាងតូចដែលលង់លក់ទៅវិញ ហើយនាយក៏ដើរមករករីណាដែលកំពុងអង្គុយចាំ ញញឹមដាក់គ្នាបន្តិច វិមន្តដាក់ខ្លួនអង្គុយប្រកៀករីណា។

- ធ្ងន់ណាស់នាងតូចនេះ! មិនដឹងជំពាក់អ្វីទេថ្ងៃនេះឱ្យបីផងអៀវផង។

- ហាសហា... កុំរអ៊ូ! តិចលោក្រោកមកវ៉ៃក្បួតឈាមទៀតឥឡូវហើយ។

- រីណា! រីណា! នាងតូចហ្នឹងនិយាយមិនខុសមែន យប់ហ្នឹងមានទេពច្យុតមែនមើលហ្ន៎!

- ខ្ញុំប្រាថ្នាសិន!

អ្នកទាំងពីរក្រោកឈរបិទភ្នែកសំពះមួយភ្លែត ភ្នែកមួយគូសម្លឹងមើលមុខវិមន្តៈ

- ប្រាថ្នាអ្វីហ្នឹង វិមន្ត?

- យី! តាមសួរទៀត!

- ចង់ដឹងហ្នឹងហើយ!

- មិនប្រាប់ទេ!

- ចិត្តអាក្រក់ម្ល៉េះ?

- ខ្លាចមិនស័ក្តិសិទ្ធិណា!

- ចុះថាមិនជឿទេ ឥឡូវចេះខ្លាចមិនស័ក្តិសិទ្ធិឯណា!

វិមន្តញញឹមតិចៗសម្លឹងមើលទៅវិរិយ៉ា "មើលហ្ន៎! អ្នកចង់ប្រាថ្នាជាងគេ គេងលក់ធ្វើមិនដឹង!"

- ហាសហា ចាំមើលតែគេដឹង គេមុខតែស្តាយណាស់ហើយ។

- តាមពិតទេពច្បុតស្អាតណាស់តើ ហ្ន៎វីណា!

- មែនហើយស្អាតណាស់ សំណាងហើយដែលបានឃើញ

ត្រូវអរគុណវិរិយ៉ាហើយ មែនហើយ! តស់យើងទៅវិញទៅ ខ្យល់ខ្លាំងត្រជាក់ណាស់។

- តស់អ៊ីចឹង! ទៅដាស់ស្រីតូចនោះសិន មើលចុះគេងលក់ស្រួលណាស់!

អ្នកទាំងពីរដើរមកដាស់វិរិយ៉ាកំពុងគេង។

- វីរិយ៉ា! ភ្ញាក់ឡើង តស់! យើងទៅវិញ។ (វីណា)

នាងតូចប្រែខ្លួន ងាកចេញពីសំឡេងរំខាន ឆ្លើយទាំងភ្នែកមិនបើក។

- ចង់គេងនៅទីនេះហើយ ត្រជាក់ស្រួលណាស់។ (វីរិយ៉ា)

- នែ៎ស្រីតូច! ក្រោកភ្លាម ខ្ញុំមិនអៀវទៀតទេណា! (វិមន្ត)

វីណាទាញដៃវីរិយ៉ាឱ្យអង្គុយទាំងខ្ជិល វីរិយ៉ាចងចិញ្ចើមធ្វើមុខស្អុយ។

- ស្តាយដល់ហើយវីរិយ៉ា អត់បានឃើញទេពច្បុត។ (វិមន្ត)

- ទេពច្បុតចុះហើយ? (វីរិយ៉ាភ្លាត់សំឡេង រត់ទៅមាត់សមុទ្ររកមើលតាមវិមន្តប្រាប់)

- គ្មានទេពច្បុតទៀតទេវីរិយ៉ា! មកវិញ!(វីណាស្រែកហៅ)

- ឯណាថាមានទេពច្បុត? វិមន្តចេះលេងសើចមនុស្សគេងទៅកើតដែរ! ដឹងទេថាខ្ញុំទន្ទឹងយ៉ាងណា! (វីរិយ៉ានិយាយទាំងខឹង ភ្នែកសម្លក់វិមន្ត)

- មិនកុហកទេ! មានមែន តែវីរិយ៉ាគេងលក់បាត់ហើយ។ (វិមន្ត)

- ម៉េចក៏មិនដាស់ខ្ញុំ? (វីរិយ៉ានិយាយទាំងខឹង)

- ដាស់ឯងទាន់ទេ? ទេពច្យុតអាចចាំឯងភ្ញាក់ទេ? មើលតែដាស់អម្បាញ់មិញហ្នឹងទៅ ដឹងហើយ។ (វីណា)

- អ្នកនាងអើយ! ខ្មាសគេណាស់ ហ្នឹងឬទន្ទឹង? (វិមន្ត) វីរិយ៉ាលែងស្ដីអង្គុយធ្វើមុខស្មុយ ត្រូវផ្លែផង ខកបំណងផង។

- កុំខូចចិត្តពេកមើល៍! នៅមានឱកាសទៀត លើកក្រោយមកទៀតខ្ញុំធានាត្រៀមកាហ្វេជូន មិនឱ្យវីរិយ៉ាគេងលក់ចោលទេពច្យុតទៀតទេ។ (វិមន្តលួង)

- មកអ្នកនាង! កុំកើតទុក្ខពេក! (វីណាតឿនទាំងអូសដៃវីរិយ៉ាដើរទៅ)

វីរិយ៉ាអត់មានស្ដីអ្វីមួយម៉ាត់ ដើរតាមមិត្តទាំងពីរដល់អូតែល។

- ហ្ន៎! អ្នកនាងទាំងពីរ! រាត្រីសួស្ដីណា! បន្ទប់ខ្ញុំនៅជាប់នេះ មានរឿងអ្វីគោះទ្វារកុំខាន។ (វិមន្ត)

- ដឹងហើយ! រាត្រីសួស្ដីលោកប្រុសឆ្នើម! (វីណាតបហើយ

វេក្អែកសម្លឹងទៅវីរិយ៉ា )

វីរិយ៉ាមិនខ្វល់ឆ្លើយឆ្លងនឹងមិត្តទាំងពីររបស់នាង ដើរចូលបន្ទប់បាត់ធ្វើព្រងើយ។ទាំងពីរនាក់ឈរមើលមុខគ្នាហួសចិត្តនឹងនិស្ស័យក្មេងរបស់នាងតូច។ ទៀបភ្លឺទៅហើយ វីរិយ៉ាគេងប្រាសចុះឡើងនៅគ្រែម្ខាង ឯវីណាដោយអស់កម្លាំងពេក គេងលង់លក់លែងដឹងអ្វី។ សំឡេងសារទូរសព្ទបន្លឺឡើងទាំងយប់ វីរិយ៉ារអ៊ូម្នាក់ឯងតិចៗ "អ្នកណាហ្នឹងផ្ញើសារទាំងយប់" ៖

- គេងមិនលក់ទេមែនទេស្រីតូច ?
- យី ! ម៉េចក៏ដឹង ?
- មនុស្សខកបំណងអ៊ីចឹងហើយ !
- ចុះវិមន្តខកបំណងរឿងអ្វីដែរ បានជាមិនទាន់គេង ?
- ខ្ញុំសមបំណងទៅវិញទេ !
- មានអ្វីពិសេស ?
- គិតមើលខ្លួនឯងទៅ !

វីរិយ៉ាអានសារហើយនឹកដល់ពេលដែលវិមន្តអៀវនាងដើរកាត់ផ្ទេរ នឹកអៀនតិចៗមិនតបសារវិមន្តទៀត សំងំគេងលក់បាត់ ភ្លេចរឿងខកបំណងមិនបានបន់ទេពច្បុត។

ម៉ោង១០ព្រឹក ទេសចរក្រុមតូចពីយប់មិញកំពុងរៀបចំចេញដំណើរមកភ្នំពេញវិញ៖

- លាហើយក្រុងព្រះសីហនុ! លាហើយសមុទ្រ! ជួបគ្នាឆាប់ៗទៀតណា!(សំឡេងស្រែករបស់វីរិយ៉ាពីមុខទ្វារឡាន)

- មិនដឹងស្អីទេ! មិនព្រមដាច់អាល័យសោះ ចូលឡានទៅ! (វីណាបង្អាប់មិត្ត)

- វីរិយ៉ា បើចូលចិត្តសមុទ្រម្ល៉ឹងៗ ប្ដូរមករស់នៅទីនេះវិញទៅ! (វិមន្ត)

- ទេ! ទេ! មិនបានទេ! បានអ្នកណាជួយធ្វើការខ្ញុំ? (Bryant ខំតសម្ដី)

- អ្នកទាំងអស់គ្នាកុំបានសម្ដីពេក! ខ្ញុំមិនអស់ចិត្តរឿងទេពច្បុតយប់មិញផង។ (វីរិយ៉ា)

- មានទេពច្បុតមែនឬវីរិយ៉ា? (Bryantសួរបញ្ជាក់)

- គឺមានមែនណា Bryant ។ (វីណា)

- តែអ្នកចាំទេពច្បុតគេងលក់បាត់ទៅហើយ។ (វិមន្តបន្ទរ)

អ្នកទាំងបីសើចនឹងពាក្យចុងក្រោយរបស់វិមន្តចំអកឱ្យស្រីតូចដែលកំពុងអង្គុយធ្វើមុខស្អុយ។

ដំណើរពីក្រុងព្រះសីហនុត្រឡប់ទៅភ្នំពេញវិញ នៅក្នុងឡាន អ្នកទាំងបួនតែងមានប្រធានបទសន្ទនាមិនឈប់ឈរ ឡានតូចក្នុងល្បឿនលឿនគួរសម មិនយូរប៉ុន្មានបានមកដល់គោលដៅ។ Bryant ដោយមានកិច្ចការបន្ទាន់ក៏ជាអ្នកចុះមុន នៅសល់រីណានិងវីរិយ៉ាដែលវិមន្តត្រូវជូនទៅផ្ទះបន្ត។

- ស្រីៗ! អ្នកណាមានការងារអ្វីបន្ទាន់ទៀត? (វិមន្តសួរ)

- ខ្ញុំ! (វីរិយ៉ាឆ្លើយរហ័ស)

- ឯងប្រញាប់ទៅណាវីរិយ៉ា? (រីណា)

- គ្រាន់តែចង់ឱ្យឆាប់បានទៅផ្ទះហ្នឹងណា។ (វីរិយ៉ា)

- តែនេះនៅជិតផ្ទះខ្ញុំជាងហ្នឹង? ម៉េចមិនឱ្យខ្ញុំចុះមុនទៅ? (រីណា)

- មែនហើយវីរិយ៉ា! ចាំបាច់ខ្ញុំបត់ឡានចុះឡើងធ្វើអី? (វិមន្ត)

- អ៊ីចឹងចាំបាច់សួរដែរ? (វីរិយ៉ាឆ្លើយបែបងរង៉ក់)

វិមន្តសើចហួសចិត្តបន្តិច នាយបត់ចង្កូតឡានសំដៅទៅផ្ទះរីណាដែលមិនឆ្ងាយប៉ុន្មានពីខុនដូBryant ស្នាក់នៅ។

- នែ៎នាងតូច! កុំងរង៉ក់ខ្លាំងពេក ទុកកម្លាំងធ្វើការស្អែកផង ខ្ញុំដល់ផ្ទះមុនហើយណា។ (រីណា)

- គ្មានងរស្អីទេ! ចេះតែថាឱ្យខ្ញុំហើយ ឯងសម្រាកទៅ ស្អែកជួបគ្នា។ (វីរិយ៉ា)

- អរគុណហើយវិមន្តដែលខំជូន! ស្អែកជួបគ្នាណាទាំងពីរនាក់! (រីណានិយាយលាទៅមិត្តទាំងដៃបើកទ្វារឡានចុះចេញទៅ)

- ជាកាតព្វកិច្ចរបស់សុភាពបុរសទេរីណា! ហេហេ... ស្អែកជួបគ្នា។ (វិមន្តក្លែមពាក្យបៀបខិល)

- ឆ្អើមណាស់សុភាពបុរស! ជូនខ្ញុំដល់ផ្ទះឱ្យលឿនទៅ! (វីរិយ៉ានិយាយស៊កឱ្យវិមន្តស្របពេលនាយកំពុងបង្វិលចង្កូតឡានចេញពីផ្ទះរីណា)

- ឆ្អើមខ្ញុំផងឬស្រីតូច? មិនទាន់ចង់ជូនទៅផ្ទះទេ! ចង់នាំទៅញុំាអីបន្ត។ (វិមន្ត)

- យី! ម៉េចមិនជូន? មិនចង់ញុំាទេ ទៅផ្ទះទៅ! (វីរិយ៉ា)

- បើអ៊ីចឹងប្រាប់មក! ហេតុអ្វីយប់មិញមិនតបសារ? (វិមន្ត)

- គេងលក់ហ្នឹងណា។ (វីរិយ៉ាឆ្លើយទាំងអឹមអៀននាងឱនមុខចុះដៃកេះក្រចក)

អាចយល់ការ វិមន្តរាដៃវែកសក់ឱ្យស្រី នាងតូចងើបមើលមុខមិត្តកំលោះជាមួយកែវភ្នែកចម្លែក មិនចង់បង្អួសពេលទៀត វិមន្ត ហាក់ដូចជាចង់ចាប់ផ្ដើមមនោសញ្ចេតនាអ្វីជាមួយស្រីតូចក្រមិចក្រមើមម្នាក់នេះ នាយចាប់ដៃវីរិយ៉ាអង្អែលថ្នមៗរៀបនឹងនិយាយ តែត្រូវនាងតូចដកដៃមកវិញយ៉ាងលឿន ព្រមជាមួយសម្ដី៖

- នែ៎ ប្រយ័ត្នខុសផ្លូវ! (វីរិយ៉ា)

- ពិតជាអត់ចង់ទៅញ៉ាំអ្វីបន្តិចសិនមែនឬ? (វិមន្តសួររបៀបតេស្តចិត្ត)

- អត់ទេ! ចង់ទៅផ្ទះ! ហត់ណាស់ណា! (វីរិយ៉ា ស្ទើរអៀនស្ទើរខឹង)

- ដាច់ចិត្តណាស់ស្រីតូច! ដល់ផ្ទះហើយចុះទៅអ្នកនាង។ (វិមន្តឌឺ)

- យើស! ដេញខ្ញុំផង ទៅហើយមិនបាច់ដេញទេ! (វីរិយ៉ាតបទាំងង៉ក់ងរ ចុះពីឡានធ្វើមិនដឹង)

វិមន្តសើចហួសចិត្តនឹងចរិតក្មេងខ្ចីរបស់វីរិយ៉ា នាយបើកកញ្ចក់ទ្វារឡាននិយាយទៅនាង មុននាងដើរចូលផ្ទះ៖

-វិរិយ៉ា បើមិនញ៉ោះខ្លះ មិនព្រមបញ្ចេញចរិតគួរឱ្យស្រលាញ់ឱ្យគេឃើញទេ។

វិរិយ៉ាសែនក្នាញ់អ្នកកំលោះ នាងឈរសម្លក់មួយភ្លែត ហើយចូលផ្ទះបាត់ទៅ។ វិមន្តក្រោយអង្គុយសម្លឹងទ្វារផ្ទះកូនក្រមុំគេមួយសន្ទុះទើបបើកឡានចេញទៅ។



- សុំទោសបង កុំប្រកាន់ខ្ញុំអី ការងារជាជីវិតខ្ញុំហើយ។
- អនាគតទៅ មិនអាចធ្វើប្រពន្ធបានទេ វីរីយ៉ា!
- តែអាចធ្វើអ្នកជំនួញដ៏ល្អម្នាក់! ជាមនុស្សស្រីដ៏អស្ចារ្យ!

វគ្គ២

# ជំហានទីមួយ

កាន់ទូរសព្ទចុចចុះឡើងបន្តិចក៏ដាក់ចុះ បន្តិចក៏លើកកាន់ ហើយក៏ដាក់ចុះវិញ មួយសន្ទុះក៏មានសំឡេងសារមួយផ្ញើមក ធ្វើឱ្យវិមន្តសើចស្រស់លើកទូរសព្ទចុចសារអាន។

- វិមន្តគេងឬនៅ ? ហត់ណាស់ហើយមែនទេ ? បើកឡានពេញមួយថ្ងៃគួរតែហត់ហើយ។ ឆាប់គេងទៅណ៎ា ស្អែកត្រូវធ្វើការ សុបិនល្អ! ស្អែកជួបគ្នា។

អ្នកកំលោះអានសារទាំងមុខមិនសូវសមបំណង។

- អរគុណរីណា សុបិនល្អដូចគ្នា ស្អែកជួបគ្នាណ៎ា!

ដាក់ទូរសព្ទចុះវិញដើរទៅបើកទូទឹកកក យកទឹកមកក្រេបបន្តិច សំឡេងសារមកមួយទៀតរោទ៍ឡើង។ នាយដូចជាលែងអើពើ ដើរមកបើកកុំព្យូទ័រឆែកអ៊ីមែលមើលការងារ

ខ្លះៗ ឃើញអ៊ីមែលរបស់ Bryant ផ្ញើរូបថតនៅសមុទ្រ ឱ្យពួកគេ។ នាយនិយាយម្នាក់ឯងតិចៗ "សមជាមេមែន! លឿនណាស់ Bryant!" វិមន្តអង្គុយមើលរូបថតដែលគេចូលចិត្តខ្លាំងជាងគេ នោះជារូបមួយដែល Bryant ថតពេលគេកំពុងអៀវស្រីតូចវីរិយ៉ា មានទាំងវីណាជាអ្នកជួយកាន់ស្បែកជើងនោះផង នាយសើចគ្រវីក្បាលនឹកឃើញកាយវិការដែលគួរឱ្យស្រលាញ់របស់ វីរិយ៉ា។ ស្ទុះស្ទាទៅយកទូរសព្ទបំណងចង់ចម្លងរូបនេះបញ្ចូល។ ចាប់ទូរសព្ទកាន់ ចុចឆែកសារដែលផ្ញើមកជាយូរភ្លាត់ម៉ាត់ "ហ្អា!ស្រីតូចទេ? ព្រះអើយ យូរហើយមិនអាន ស្មានតែអ្នកផ្សេង!"

- ថ្ងៃក្រោយកុំធ្វើអ៊ីចឹងទៀត។

វិមន្តញញឹមស្រស់តបសារទៅអ្នកនាងតូចវិញ៖

- ធ្វើអ្វី? និយាយដូចគ្មានមនោសញ្ចេតនាសោះ។

- រយលានឆ្នាំហើយទើបមកឆ្លើយ! គេងទៅយប់ហើយ។

- ឈប់! ឈប់សិន! និយាយគ្នាបន្តិចទៅស្រីតូច។

- មានអ្វីចង់និយាយ? ចាំស្អែកទៅ គេងហើយ។

- មិនចង់គេងទេ ចង់និយាយគ្នាពីរបីម៉ាត់សិនណា? វីរិយ៉ាព្រះនាងតូចរបស់ខ្ញុំអើយ!

អ្នកទទួលសារមិនខ្វីឆ្លើយ ធ្វើចិត្តរឹងតែគេងញញឹមរហូតលង់លក់ ឯអ្នកផ្ញើសារអង្គុយចាំគេយូរទៅកាន់តែយូរទៅដឹងច្បាស់ថាគេចិត្តដាច់ទៀតហើយ ក៏រៀបចំគេងឱបទូរសព្ទមើលរូបថតជាទីស្រលាញ់រហូតលង់លក់ដែរ។

ព្រឹកថ្ងៃចន្ទដ៏រវល់មនុស្សម្នារត់ចុះឡើងក្នុងការិយាល័យម្នាក់ៗកំពុងយកចិត្តទុកដាក់លើកិច្ចការរៀងៗខ្លួន។ នៅក្នុងបន្ទប់ធ្វើការរបស់ Bryant មានវីរិយ៉ាកំពុងឈរតវ៉ា៖

- តែខ្ញុំបានណាត់គាត់រួចហើយ គាត់ជាមនុស្សពិបាកណាត់ជួបណាស់ Bryant កុំលើកការណាត់នេះបានទេ?

- តែខ្ញុំមានប្រជុំបន្ទាន់។

- តែគាត់ជាភ្ញៀវសំខាន់ណ៎ា!

- ស្រីតូច! ឥឡូវហ៊ានទៅម្នាក់ឯងទេ? ខ្ញុំឱ្យសិទ្ធិទៅនាងមកនេះខ្ញុំបង្រៀនរបៀបគិតតម្លៃ ហើយនាងតូចអាចសម្រេចចិត្តបានហើយ។

វីរិយ៉ាធ្វើមុខស្ទាក់ស្ទើរ តែដើរទៅជិតទទួលការពន្យល់របស់ Bryant យ៉ាងយកចិត្តទុកដាក់ សៀវភៅតូចមួយកត់ត្រាយ៉ាងប្រយ័ត្ន។

- Bryant! ខ្ញុំយល់ហើយតែដូចជាស្ទាក់ស្ទើរណាស់ បើមិន
ច្បាស់អ្វី ឱ្យខ្ញុំខលមកបានទេ?

- យើងអាចផ្ញើសារបាន ព្រោះខ្ញុំមានប្រជុំមិនគួរនិយាយទូរសព្ទទេ។

- ចាំ! (ជាមួយទឹកមុខភ័យៗ)

- កុំបារម្ភពេក! វីរីយ៉ាអាចធ្វើបាន!

- តែគាត់ជាភ្ញៀវធំណាស់ បើបាត់បង់ខ្ញុំមុខតែស្លាយខ្លាំងណាស់។

- រឿងអ្វីក៏មានលើកទី១ដែរ ធ្វើឱ្យបានទៅ! ខ្ញុំដល់ម៉ោងហើយ នាងទៅចុះ!

វីរីយ៉ាមានកាយវិការប្រញាប់ប្រញាល់រៀបចំឯកសារ និងកុំព្យូទ័រយួរដៃដើរយ៉ាងលឿនសំដៅទៅឡាន ជួបជាមួយវិមន្ត ខំញញឹមស្វាញទៅរកនាងៈ

- ទៅណាលឿនម្ល៉េះស្រីតូច?

- កុំសួរ រវល់ណាស់!

អ្នកនាងវីរីយ៉ាបើកទ្វារឡានចូល ហើយបើកឡានចេញទៅយ៉ាងលឿន វិមន្តមិនប្រកាន់នឹងកាយវិការនេះដែរ

ព្រោះគេស្គាល់ចរិតនាងទៅហើយ។ នាយដើរចូលទៅក្នុងការិយាល័យ
សំដៅទៅរកវីណាដែលកំពុងផ្តោតអារម្មណ៍ធ្វើរបាយការណ៍ ៖

- វីយ៉ាមិនដឹងមានភ្ញៀវសំខាន់ប៉ុនណាទេ ប្រញាប់ដល់ហើយ សួរមួយម៉ាត់មិនឆ្លើយផង!

- នាងតូចហ្នឹងឱ្យតែដល់ម៉ោងធ្វើការគេមិនខ្វល់មិត្តភក្តិស្អីទេ ការងារជាជីវិតនាងហើយ តែវីណាជាមិត្តល្អរបស់នាង ហេតុអ្វីមិនដូចគ្នា?

- ខ្ញុំមានបេះដូងណ៎ា! ធ្វើមិនដូចនាងតូចនោះទេ!

- ហាសហា វីយ៉ាគ្មានបេះដូងទេ?

- ប្រហែលហើយ នាងប្រគល់ឱ្យសមុទ្រអស់ហើយ ហាសហា...! វិមន្តក៏ជាមិត្តល្អរបស់នាងដែរ មកសួរខ្ញុំទៅកើតដែរ!

- ដឹងពីនាងមិនដល់វីណាឯណា! ហើយកំពុងធ្វើអ្វីនេះ?

- ធ្វើការណ៎ា! របាយការណ៍នេះធ្វើមិនចប់សោះ គង់តែBryant បន្ទោសទៀតហើយ មិនដឹងធ្វើយ៉ាងម៉េចឱ្យពូកែដូចនាងតូចនោះទេ មិនចេះត្រូវមាត់សោះ។

- អ៊ីចឹង ម៉េចមិនដកបេះដូងទៅផ្ញើនៅសមុទ្រដូចវីរិយ៉ាដែរទៅ ហាសហា...!

- យី! វិមន្តនេះ ទៅៗ! ទំនេរដល់ហើយហ្ន៎!

- មិនទំនេរទេ មានរឿងត្រូវសួរ Bryant តែបើមិនព្រមចេញពីប្រជុំអ៊ីចឹងមិនដឹងសួរយ៉ាងម៉េចទេ!

- កុំចាំអី! ស្រីតូចទើបតែខឹង Bryant រឿងនេះហើយ ចង់ផ្អាកការណាត់ជាមួយភ្ញៀវធំរបស់នាង!

- ចប់ហើយអ៊ីចឹង អ្នកនាងជំនួយការជួយខ្ញុំផងទៅ!

- ស្អីអ៊ីចេះនេះ! ខ្ញុំមានសិទ្ធិអ្វី!

វិមន្តដើរទាំងអស់សង្ឃឹមទៅតុខ្លួនឯងបោកសៀវភៅតូចនឹងដៃ បញ្ចេញកាយវិការរបៀបតប់ប្រមល់ វីណាមិនខ្វល់គិតតែរវល់ជាមួយរបាយការណ៍របស់នាងដែលធ្វើមិនចប់ម្នាក់ៗដូចជាលែងមានមនោសញ្ចេតនាក្នុងខ្លួនដូចកាលទៅលេងសមុទ្រអស់។

វីរិយ៉ាឯណោះបើកឡានទៅដល់កន្លែងជួបភ្ញៀវសំខាន់នាងតូចភ័យអរ បារម្ភនឹងការណាត់ជួបមួយនេះ ណាមួយជាលើកទី១ ដែលជួបភ្ញៀវសំខាន់បែបនេះតែម្នាក់ឯងផងណាមួយខ្លាចមិនអាចជោគជ័យ តែនាងនៅតែត្រេកអរនឹង

សិទ្ធិធំដែល Bryant បានប្រគល់ឱ្យនាងក្នុងគម្រោងមួយនេះ។ បើនាងធ្វើបាន នាងមិនដឹងមានមោទកភាពយ៉ាងណាទេ។ ភ្ញៀវសំខាន់រូបសង្ហាបានមកដល់៖

- សួស្តីបាទ ខ្ញុំគឺបញ្ញវន្ត! ប្អូនជាវីរិយ៉ាឬ?

- ចាំសួស្តីបង គឺខ្ញុំ វីរិយ៉ា!

- សុំទោសណាដែលឱ្យចាំយូរ!

- ចាស មិនថ្វីទេបង!

បន្ទាប់ពីការប្តូរនាមប័ណ្ណអ្នកទាំងពីរបន្តចរចាពិភាក្សានៅលើកុងត្រាដ៏សំខាន់មួយនេះ វីរិយ៉ាចាប់ផ្តើមបែកញើសតិចៗនៅក្នុងម៉ាស៊ីនត្រជាក់ ដែលមានសីតុណ្ហភាពត្រជាក់ល្មម មានម៉ាស៊ីនគិតលេខផង បើកសៀវភៅតូចរបស់នាងផង ដូចជាញើរញ័របន្តិចតែពោរពេញទៅដោយភាពក្លៀវក្លានៅលើកុងត្រាធំមួយនេះ។ បញ្ញវន្តដែលជាភ្ញៀវសំខាន់លើកពែងកាហ្វេក្រេបសម្លឹងមើលភាពសកម្មរបស់វីរិយ៉ាក្នុងការកោតសរសើរ ៖

- បង!ខ្ញុំគិតរួចហើយ បែបនេះពិបាកបន្តិចណ៎ា ឥឡូវខ្ញុំជូនបងនូវលក្ខខណ្ឌមួយនេះវិញ បងមើលបន្តិចទៅ។ (នាងតូច បង្វែរកុំព្យូទ័រទៅបញ្ញវន្ត)

- បើសិនជាអាចដូចខ្ញុំស្នើទៅប្រហែលស្រួលនិយាយគ្នាបន្តិចណាវិរិយ៉ា។ (នាយនិយាយបណ្តើរទទួលកុំព្យូទ័រពីនាងយកមកអានកុងត្រាយ៉ាងលម្អិត)

វិរិយ៉ានិយាយផ្អែមនិងគួរសម ដើម្បីបន្ទន់ចិត្តអតិថិជនធំ ៖

- បង! នេះខ្ញុំពិតជាខំអស់ពីសមត្ថភាពហើយណ៎ាបង(នាងតូចលើកកែវកាហ្វេក្រេបបន្តិចឱ្យបាត់ស្ងួតបំពង់ក) បងមើលលក្ខខណ្ឌដែលខ្ញុំផ្តល់នេះចុះ មិនខុសពីអ្វីដែលបងសុំ ប៉ុន្មានទេ មិនគួរបងស្ទាក់ស្ទើរទេបង។

បញ្ញវន្តញញឹមតែមិនតប ធ្វើឱ្យវិរិយ៉ាកាន់តែបុកពោះ ដៃដាក់លើភ្លៅលួចធ្វើតក្រចកមើលទំនងដូចជាអន្ទះសាខ្លាំងណាស់ មួយភ្លែតនាងលួចសម្លឹងមើលភ្ញៀវកំលោះទាំងមិនទុកចិត្តខ្លួនឯង តែបានត្រឹមតែអង្គុយញញឹមតិចៗយ៉ាងគួរសមរង់ចាំការឆ្លើយតបពីបញ្ញវន្ត។ អានកុងត្រាចប់ អ្នកកំលោះមិនផ្លាស់ប្តូរទឹកមុខឱ្យវិរិយ៉ាបានទុកចិត្តសោះ នាយបង្វែរកុំព្យូទ័រទៅឱ្យស្រីតូចយើងវិញ។ វិរិយ៉ាទទួលទាំងកែវភ្នែកអន្ទះសាតែមិនសួរអ្វីសោះ ព្រោះចង់លាក់អារម្មណ៍ខ្លះកុំ

ឱ្យអ្នកកំលោះនោះបញ្ចេញអំនួតជាភ្ញៀវធំខ្លាំងជាងនេះទៀត។ អ្នកកំលោះលើកដៃមើលនាឡិកាស្ដីទៅវិរិយ៉ា៖

- ដល់ម៉ោងបាយល្ងាច តស់! ឱ្យខ្ញុំអញ្ជើញវិរិយ៉ាទៅញ៉ាំបាយមួយពេលសិនណា៎ ទៅនិយាយគ្នាបន្តនៅតុបាយទៀតទៅ!

វិរិយ៉ាទាំងទឹកមុខស្ងាក់ស្ទើររៀបចំឯកសារទៅតាមសំណើ

របស់បញ្ញាវន្ត អ្នកកំលោះបើកទ្វារបន្ទប់ប្រជុំជូននាងតូចតាមលក្ខណៈសុភាពបុរស។

- យើងទៅហាងបាយជិតនេះចុះណា។

- ចាស ឯណាក៏បានដែរបង តែខ្ញុំបើកឡានមកដែរ។

បញ្ញាវន្តតបបែបខិល៖

- អ៊ីចឹងសុំជោយសារទៅផងខ្ជិលបើកឡានខ្លួនឯង។

វិរិយ៉ាឆ្លើយគួរសម៖

- ចាស មិនប្ញីទេបង។

ដល់ឡានល្មម នាងតូចចុចបញ្ជាដោះសោពីចម្ងាយ ភ្ញៀវកំលោះបើកទ្វារឡានជូនវិរិយ៉ាចូលកាន់ចង្កូត ហើយដើរទៅចូលអង្គុយនៅកៅអីខាងមុខម្ខាងទៀត។

- សុំទោសបង ឡានមនុស្សស្រីសាំញ៉ាំបន្តិចហើយ។

- មានឯណា! ឡានមនុស្សប្រុសខ្ជិលដូចខ្ញុំនេះទើបមិនហ៊ានឱ្យវីរិយ៉ាឃើញ រកកៅអីទំនេរមិនមានទេ ហេហេ...!

វីរិយ៉ាមិនតបគ្រាន់តែញញឹមរួចបង្វិលចង្កូតចេញទៅបញ្ញវន្តជាអ្នកប្រាប់ផ្លូវរហូតដល់ភោជនីយដ្ឋានបារាំងមួយដែលពោរពេញទៅដោយអ្នកមានមុខជំនួញធំៗនៅទីនោះជួបជុំពិភាក្សាក្នុងតុអាហារ។ មានអ្នកបម្រើទាញកៅអីជូនស្រីតូចអង្គុយរៀបចំឥរិយាបថ តែក្នុងចិត្តសែនអន្ទះសាចង់សួរឱ្យច្បាស់ណាស់ថាព្រម ឬមិនព្រម នាងខ្លាចតែចាញ់គម្រោងធំមួយនេះទេ។

លើកទឹកត្រជាក់ក្រេបបន្តិច ភ្ញៀវកំលោះស្រដីទៅកាន់វីរិយ៉ាយ៉ាងគួរសម៖

- កុំខ្លាចចិត្តណា ចង់ញ៉ាំអ្វីក៏ហៅទៅ នៅទីនេះខ្ញុំណែនាំឱ្យញ៉ាំស្ពៃកសាច់គោអ៊ីតាលីចុះ!

វីរិយ៉ាញញឹមទាំងត្រូវចិត្ត៖

- ជាចំណូលចិត្តខ្ញុំហើយ!

- អ៊ីចឹងចាប់អារម្មណ៍ថែមស្រាក្រហមទៀតទេ?

- ចាស អត់ទេ! មិនអាចទេបង ថ្ងៃពេកហើយ!

អ្នកទាំងពីរសើចរបៀបហួសចិត្តរៀងខ្លួន។

- យកស៊ុបបន្លែផងទៅវីរិយ៉ា!

- អ៊ីចឹងខ្ញុំសូមស៊ុបផ្ទីចុះ!

បញ្ញាវន្តបែរទៅនិយាយជាមួយអ្នកបម្រើក្នុងហាង ៖

- អូនកត់ទៅ! យកស្តេកអ៊ីតាលី២ ស៊ុបផ្ទី២ សាឡាដ១ រួចការកុម្មង់នាយបែរទៅនិយាយជាមួយវីរិយ៉ាវិញ។

- វីរិយ៉ាមានអ្វីបន្ថែមទៀតទេ?

- ដូចជាអត់ទេបង!

- បងស្រី បងប្រុសតើមិនត្រូវការកុម្មង់ភេសជ្ជៈទេ?(អ្នកបម្រើ)។

- វីរិយ៉ាទឹកផ្លែឈើស្រស់យ៉ាងម៉េចដែរ? (បញ្ញាវន្ត)

- អ៊ីចឹងខ្ញុំសុំទឹកការ៉ុតចុះ! (វីរិយ៉ា)

- យី! ស្រលាញ់សុខភាពណាស់វីរិយ៉ា (នាយបន្តទៅអ្នកបម្រើ) អូនយកតាមហ្នឹងទៅហើយថែមទឹកម្នាស់ឱ្យបងផង។

អ្នកបម្រើកត់ត្រារួចរាល់ដើរចេញទៅ ភ្ញៀវមួយគូនេះមានការនិយាយឆ្លើយឆ្លងដោយទាល់តែបញ្ញាវន្តជាអ្នកផ្តើម។ អាហារលើកដាក់ពេញលើតុ បញ្ញាវន្តជាសុភាពបុរសតែង

បម្រើសេវាដល់វីរិយ៉ាយ៉ាងគាប់ចិត្ត តែនាងតូចគ្មានអារម្មណ៍ដឹងរសជាតិជាមួយម្ហូបទាំងនេះទេ បញ្ញវន្តដឹងចិត្តតាមរយៈកែវភ្នែកស្រី៖

- វីរិយ៉ាមិនឱ្យខ្ញុំញ៉ាំបាយបានស្រួលសោះ។ (បញ្ញវន្ត)

វីរិយ៉ាចងចិញ្ចើមធ្វើមុខធូល់ អ្នកកំលោះយកកុងត្រាមកស៊ីញេលើតុបាយហុចឱ្យទៅនាង ស្រីតូចសើចស្វាញទម្លាក់កាំបិតសមចុះ ទទួលកុងត្រាពីភ្ញៀវសំខាន់មើលស្នាមហត្ថលេខាទាំងញញឹមពេញចិត្តយ៉ាងខ្លាំង។

- មានចិត្តញ៉ាំអាហារមួយពេលឱ្យឆ្ងាញ់បានឬនៅវីរិយ៉ា?

នាងតូចញញឹមតែមិនស្តីឱនមុខញ៉ាំស្តេកសាច់គោដ៏មានរសជាតិរបស់នាង។ កំលោះបញ្ញវន្តមិនអស់ចិត្តពោលបន្ត៖

- គ្រាន់តែឱ្យខ្ញុំទទួលបានស្នាមញញឹមដ៏ស្មោះត្រង់ក្នុងអាហារថ្ងៃកំណើតក៏មិនបានដែរ។

វីរិយ៉ារបៀបភ្ញាក់ផ្អើល នាងសម្លឹងទៅបញ្ញវន្តទាំងធូល់៖

- ហេតុអ្វីបងមិនមានណាត់ពិសេសជាមួយមនុស្សពិសេសឬគ្រួសារ?

- បើមាន មិនចាំបាច់មកញ៉ាំបាយជាមួយមនុស្សទើបជួបគ្នាលើកទី១ដូចជាវីរិយ៉ានេះទេ។ គ្មានចិត្តចង់បានមិត្តភាពជាមួយខ្ញុំទេ គិតតែរឿងការងារពេកហើយ។

- អត់ទេ! អត់ទេបង! កុំនិយាយអ៊ីចឹង ខ្ញុំគិតមិនដល់នោះទេថាខ្ញុំមានឱកាសចូលរួមថ្ងៃសំខាន់ម្ល៉ឹងរបស់បង ធម្មតាថ្ងៃនេះគឺសម្រាប់តែអ្នកពិសេសហ្នឹងណា។

- ហ្នឹងហើយ ព្រោះខ្ញុំមិនមានទើបរកជំនួយពីវីរិយ៉ា ដឹងអ្វីនាងគិតតែរឿងការងារ!

- សុំទោសបង កុំប្រកាន់ខ្ញុំអី ការងារជាជីវិតខ្ញុំហើយ។

- អនាគតទៅ មិនអាចធ្វើប្រពន្ធល្អបានទេ វីរិយ៉ា!

វីរិយ៉ាតបបែបមិនខ្វល់៖

- តែអាចធ្វើអ្នកជំនួញដ៏ល្អម្នាក់! ជាមនុស្សស្រីដ៏អស្ចារ្យ!

បញ្ចប់វគ្គគ្រវីក្បាលលេងស្តី អ្នកទាំងពីរបន្តអាហារថ្ងៃត្រង់ដោយរីករាយ។

បែរមកមិត្តទាំងពីររបស់វីរិយ៉ាបាត់នាងមួយព្រឹកតើពួកគេមានរកនាងទេ? រីណាដើរកាន់កាហ្វេទឹកកកមួយកែវចូល

អង្គុយនៅគុនាងហើយនិយាយទៅវិមន្តដែលកាន់កាហ្វេក្តៅពីរកែវ ទំនងអ្នកទាំង២ទើបមកពីញ៉ាំបាយថ្ងៃត្រង់។

- នែ៎វិមន្ត! វីរីយ៉ាបាត់ឈឹងតែម្តងហើយ ភ្ញៀវធំនោះលេបនាងបាត់ហើយទេដឹង? (វីណា)

- ហាសហា នាងតូចរបស់យើងនេះតូចតែខ្លួនទេ ចិត្តមិនតូចទេ គ្មានអ្នកណាធ្វើអ្វីនាងបានទេ។ (វិមន្ត)

- នេះវិមន្តឯងខំកាន់កាហ្វេមកឱ្យនាង មិនដឹងនាងបានញ៉ាំឬអត់ផង អ្នកស្រីវល់នោះមុខតែទុកកាហ្វេវិមន្តឯងចោលឱ្យត្រជាក់ដូចលើកមុនអ៊ីចឹង! (វីណា)

លេចរូបវីរីយ៉ាមួយពព្រិចភ្នែកដើរចូលមក រួចនិយាយទៅកាន់មិត្តៈ

- អ្នកណានិយាយដើមខ្ញុំ? អ្នកណាថាខ្ញុំទុកកាហ្វេប្រុសសង្ហាម្នាក់នេះចោលទៀត? កាហ្វេនេះឆ្ងាញ់ជាងកាហ្វេណាៗទាំងអស់ ព្រោះបានដៃវិមន្តនេះកាន់មកទាំងទឹកចិត្តណា៎!

និយាយចប់មិនទាន់ វីរីយ៉ាលើកកាហ្វេក្រេបដោយទឹកមុខយ៉ាងមានក្តីសុខ។

- អីយ៉ា! សម្តីផ្អែមណាស់វីរីយ៉ា! កុំចង់បន្ទន់បេះដូងកំលោះខ្ញុំនេះណា! (វិមន្តតបទាំងញញឹមបិទមាត់មិនជិត)

- មើលទៅរីករាយយ៉ាងនេះ មុខតែមានដំណឹងល្អហើយអ្នកនាង! (វីណានិយាយទៅមិត្តសម្លាញ់)

- បេះដូងកំលោះម្នាក់នោះទន់ស្រាប់ហើយទេដឹងវិមន្ត? (ជាសំឡេងរបស់ Bryant ចេញពីក្នុងបន្ទប់ការិយាល័យរបស់គេ)។

- យី Bryant មិនទាន់ទៅញ៉ាំបាយទេ? (វីណាសួរទាំងឆ្ងល់)។

- ទៅឯណាបើទើបតែរំសាយប្រជុំអម្បាញ់មិញហ្នឹង។ (Bryant តបទៅជំនួយការ)

- វីណាដាក់ពែងកាហ្វេចុះលើកទូរសព្ទចុចទៅផ្នែកសម្អាត
ឱ្យមករៀបចំបន្ទប់ប្រជុំ។

វិមន្តដើរទៅក្បែរ Bryant ទះស្មាមនុស្សដែលនាយគោរព
ដូចជាបងប្រុសនិងមិត្តល្អផងតិចៗរួចពោលៈ

- លោកប្រធានកុំបង្អាប់ខ្ញុំពេក អ្នកនាងវីរីយ៉ានេះខ្ញុំហាក់មិនដល់ទេ។

សម្លឹងទៅរីយ៉ាចង់ដឹងសកម្មភាពរបស់នាងបន្ទាប់ពីឮពាក្យរបស់គេ។ រីយ៉ាមិនបានចាប់អារម្មណ៍អ្នកណាក្លែមពាក្យឱ្យនាងទេ ដកឯកសារចេញពីកាបូបរត់ឆ្ពោះទៅ Bryant។

- តែន! តែន! តែន... ឃើញទេ? ជោគជ័យ! ជោគជ័យធំណាស់ Bryant ខ្ញុំសប្បាយចិត្តណាស់ណ៎ា!

- អីយ៉ានាងតូច! ធ្វើការធំបានហើយ! គ្រាន់បើណាស់ ខ្ញុំទុកចិត្តនាងមិនខុសមែនរីយ៉ា! ជិតជំនួសខ្ញុំបានហើយណា។ (Bryant អបអរនឹងជ័យជម្នះធំរបស់រីយ៉ា)

- អស្ចារ្យមែនរីយ៉ា! អបអរសាទរ។ (វិមន្តសម្តែងការរីករាយទៅនាង)

- អ៊ីចឹងកាហ្វេវិមន្តថ្ងៃនេះមានរសជាតិក៏ដោយសារតែកុងត្រាមួយនេះទេ។ (រីណាឌឺឱ្យវិមន្ត)

អ្នកទាំងអស់គ្នាបង្ហាញការរីករាយពីជោគជ័យធំរបស់រីយ៉ា។ រីយ៉ាជានារីដែលពូកែខ្លាំងក្នុងសកម្មភាពការងារបន្ទាប់ពីសម្រេចការងារធំមួយនេះមក Bryant តែងផ្តល់សិទ្ធិឱ្យនាង

ច្រើនជាងមុន វីរីយ៉ាកាន់តែមានទំនុកចិត្តក្នុងការជួបប្រជុំ
ជាមួយអតិថិជនធំៗឯទៀត ហើយនាងបានសម្រេចស្នាដៃ
យ៉ាងច្រើន។

# ការសម្រេចចិត្ត

បន្ទាប់ពីការចុះកុងត្រាក្នុងថ្ងៃកំណើត បញ្ញវន្តមិនដែល ផ្ដាច់ទំនាក់ទំនងជាមួយវីរិយ៉ាទេ ក្រៅពីរឿងការងារពួកគេ ក៏ជាមិត្តល្អនឹងគ្នា។ វីរិយ៉ាគោរពបញ្ញវន្តដូចបងប្រុសហើយ ស្ញប់ស្ញែងចំណេះដឹង និងបទពិសោធរបស់នាយណាស់ រាល់ពេលមានបញ្ហាការងារ បញ្ញវន្តតែងតែជាទីប្រឹក្សាដ៏ល្អរបស់ វីរិយ៉ា។

អាហារពេលល្ងាចមួយរបស់អ្នកទាំងពីរៈ

- ការងារមួយរយៈនេះយ៉ាងម៉េចហើយវីរិយ៉ា? (បញ្ញវន្តសួរសុខទុក្ខស្រីតូចតាមទម្លាប់)

- បងបញ្ញវន្ត! ការងារគឺល្អណាស់ តែចិត្តមនុស្សទេដែលមិនល្អ។ (វីរិយ៉ាតបទាំងទឹកមុខធុញទ្រាន់)

- យី! ម៉េចអ៊ីចឹង? (បញ្ញវន្តសួរដោយឆ្ងល់ ព្រោះវីរិយ៉ា



វីរិយ៉ាចង់បានប្រធានចិត្តល្អ ឬចង់ធ្វើប្រធានចិត្តល្អដោយខ្លួនឯង?
មិត្តភក្តិមិនអាចធ្វើការជាមួយគ្នាមួយជីវិតបានទេ
ថ្ងៃមួយដែលពួកគេរកឃើញគោលដៅគេគង់នឹងចាកចេញពីអូនដូចគ្នា
នេះគ្រាន់តែវីរិយ៉ាដើរលឿនជាងគេមួយជំហានទេ។

តែងសរសើរមិត្តនិងប្រធានរបស់នាង ឯការងារសម្រាប់នាងមានតែជោគជ័យ ហេតុអ្វីថ្ងៃនេះស្រីតូចស្រាប់តែមានអារម្មណ៍ថាធុញ?)

- បងបញ្ញវន្ត! គោលដៅរបស់ខ្ញុំមិនមែនត្រឹមជាមនុស្សស្រីដែលពូកែធ្វើការប៉ុណ្ណឹងទេណា! ខ្ញុំត្រូវតែមានក្រុមហ៊ុនមួយជារបស់ខ្លួនឯង! ខ្ញុំពូកែផ្នែកទំនាក់ទំនងហើយ ខ្ញុំមានបណ្តាញហើយ តែខ្ញុំដូចជាខ្វះសមត្ថភាពគ្រប់គ្រងនិងការស៊ើបអង្កេតផ្ទៃក្នុង បើអ៊ីចឹងថ្ងៃក្រោយខ្ញុំមានក្រុមហ៊ុនមួយជារបស់ខ្លួនឯងយ៉ាងម៉េចទៅ?

- យី! ចិត្តធំណាស់! មានការគិតច្រើនមែន ថ្ងៃក្រោយពិតជាជោគជ័យធំណាស់វីរិយ៉ា! ប្អូនចង់ឱ្យបងជួយយ៉ាងម៉េច?

- មិនដឹងទេបង! ខ្ញុំដូចជាត្រូវការការអភិវឌ្ឍហើយ។

- ឱ្យបងគិតបន្តិចសិន! (បញ្ញវន្តនិយាយទាំងយកដៃញីចិញ្ចើម)

វីរិយ៉ាមិនស្តីអង្គុយសម្តែងមុខចងចិញ្ចើមនឹងអន្ទះសា បញ្ញវន្តសម្លឹងមុខនាងមួយសន្ទុះ និយាយទៅកាន់វីរិយ៉ាទាំងមិនទុកចិត្តះ

- បងគិតថាបងមានតំណែងមួយឱ្យវីរិយ៉ា តែសម្រាប់អាយុអូន វាក្មេងណាស់សម្រាប់តំណែងមួយនេះ បងគិតថាអូននឹងអាចធ្វើបាន គ្រាន់តែត្រូវការពេលបន្តិច។

វីរិយ៉ាធ្វើមុខស្ងាក់ស្ទើរ សួរទៅវិញទាំងគ្មានទំនុកចិត្តដូចគ្នា៖

- បងគិតថាឱ្យខ្ញុំធ្វើអ្វី? ពេលបងនិយាយដល់ពាក្យនេះមានអារម្មណ៍ថាខ្ញុំត្រូវបាត់ខ្លួនពីមិត្តភក្តិរបស់ខ្ញុំ និងប្រធានដ៏ចិត្តល្អរបស់ខ្ញុំហើយ។

- វីរិយ៉ាចង់បានប្រធានចិត្តល្អ ឬចង់ធ្វើប្រធានចិត្តល្អដោយខ្លួនឯង? មិត្តភក្តិមិនអាចធ្វើការជាមួយគ្នាមួយជីវិតបានទេ ថ្ងៃមួយដែលពួកគេរកឃើញគោលដៅគេគង់នឹងចាកចេញពីអូនដូចគ្នា នេះគ្រាន់តែវីរិយ៉ាដើរលឿនជាងគេមួយជំហានទេ។

ស្រីតូចវីរិយ៉ាប្រែទឹកមុខជាស្រពោនហើយសួរបញ្ជាក់៖

- បងបញ្ញវន្ត ចុះហេតុអ្វីបងចិត្តល្អជាមួយខ្ញុំ? ដឹងថាខ្ញុំក្មេងដែរ ចង់លើកខ្ញុំក្នុងតំណែងធំ ហ្ម៎! តំណែងអ្វីទៅបង?

- បងគ្រាន់តែចង់ជួយក្មេងស្រីខ្លួនតូចមហិច្ឆតាធំដូចប្អូននេះ ចង់ឱ្យបានសម្រេចដូចបំណងហ្នឹងណ៎ា។

- ខ្ញុំអាចទេបង?

- យី! ពីដើមមកមានជំនឿចិត្តណាស់ ម៉េចថ្ងៃនេះមកសួរបងអ៊ីចឹងវិញ?

- ខ្ញុំស្រាប់តែមានអារម្មណ៍ភ័យណាស់បង ឬក៏ខ្ញុំគួរតែចាំមួយឆ្នាំពីរទៀត? (វីរិយ៉ាសួរទាំងគ្មានទំនុកចិត្ត)

- នែ៎ស្រីតូច! ឱកាសមិនមែនចេះតែមាន! បើប្អូនមិនចាប់យកវាទេ វានឹងធ្វើឱ្យប្អូនស្តាយក្រោយ! បើអូនចង់ចាំអូនចាំចុះ តែអូនត្រូវចាំថា អូនចាប់ផ្តើមយឺតអូននឹងខាតបង់ដូចគ្នា។

- ខាតយ៉ាងម៉េចទៅបង? (វីរិយ៉ាសួរប្រដេញ)

- ក្នុងនាមបងជាអ្នកជំនួញម្នាក់ ថ្ងៃនេះបងមានឱកាសរកបានមួយលានដុល្លារ ប៉ុន្តែបងដូចជាចង់ចាប់ផ្តើមថ្ងៃស្អែកវិញអ៊ីចឹងតើមួយលានដុល្លារនោះវារត់ចូលហោប៉ៅបងថ្ងៃនេះទេ? វាអាចរត់ចូលថ្ងៃស្អែក តែបើបងចាប់ផ្តើមពីថ្ងៃនេះ បងនឹងបានពីរលាននៅថ្ងៃស្អែក បើបងគិតដូចអូនអ៊ីចឹងគឺបងបាត់មួយលានព្រោះតែបងយឺត។ ចុះបើប្អូនជាអ្នករកបទពិសោធ អូនថាខ្លួននៅក្មេងចង់ចាំមួយឬពីរឆ្នាំទៀត ទើបយកតំណែងធំដែលបងឱ្យ អ៊ីចឹងពីរឆ្នាំទៀតទើបចាប់ផ្តើមរកបទពិសោធដែលខ្វះ ចុះអូនត្រូវប្រើពេលប៉ុន្មានឆ្នាំដើម្បី

សិក្សាពីបទពិសោធដែលខ្វះនោះ? ហើយត្រូវប្រើពេលប៉ុន្មានឆ្នាំទៀតទើបអាចបង្កើតមុខជំនួញខ្លួនឯងបាន? អូនចង់ធ្វើមនុស្សស្រីដែលជោគជ័យក្នុងអាយុ៦០ឆ្នាំមែនទេស្រីតូច?

នាងតូចវីរិយ៉ាសើចទាំងជ្រួតជ្រាប ៖

- បងបញ្ញវន្ត! ខ្ញុំយល់ហើយ ប្រហែលខ្ញុំក្មេងអ៊ីចឹងមិនឆ្លាតទេ តំណែងធំមុខតែត្រូវការពេលយូរក្នុងការរៀនគ្រប់គ្រងមនុស្ស មិនស្រួលទេមែនទេបង?”

- សាកមើលសិនទៅ បងនឹងជួយប្អូន។

- ម៉េចក៏បងចិត្តល្អម្ល៉េះបង? បងឱ្យខ្ញុំកាន់ផ្នែកអ្វី?

- ប្រធានចាត់ការទូទៅ អូននឹងមិនមែនជាជំនួយការអ្នកណាទាំងអស់ ហើយក៏គ្មានជំនួយការខ្លួនឯងដែរ អូនត្រូវមើលការងារទាំងអស់ជំនួសបងដែលជាប្រធានក្រុមហ៊ុន លេខារបស់បងនឹងពន្យល់ ហើយជួយអូនតិចតួចក្នុងករណីអូនមិនយល់។

- ហេតុអ្វីបងមិនឱ្យអូនមានជំនួយការ?

- ព្រោះបងចង់លត់ដំអូន ចង់ឱ្យអូនធ្វើការផ្ទាល់ជាមួយបុគ្គលិកក្រោមបង្គាប់ពិនិត្យ និងធ្វើរបាយការណ៍ទាំងអស់

ដោយខ្លួនឯង។ អូននឹងត្រូវហាត់ នឹងទទួលសម្ពាធខ្លាំងជាង កិច្ចការងារដែលអូនកំពុងធ្វើនេះច្រើនដង គិតមើលទៅ អាច ទេ?

- មុខតែអាចហើយបង! តែដូចជាធំពេកហើយ វាមុខតែ ពិបាកខ្លាំងសម្រាប់ខ្ញុំ បើខ្ញុំស្រាប់តែមានគំនិតក្មេងខ្ចី បោះបង់ចោលកណ្ដាលទី?

- អ៊ីចឹងហើយទើបបងឱ្យប្អូនគិត! ទឹកចិត្តបងធំណាស់ សម្រាប់ វីរិយ៉ា បើធ្វើមិនបានប៉ុន្មានក៏ស្រាប់តែបោះបង់ តើ អូននឹងបំផ្លាញទឹកចិត្តបងនេះប៉ុនណាទៅ?

- បង! ចុះបើពេលនេះខ្ញុំបដិសេធ? (វីរិយ៉ាមិនទាន់ចាប់ ផ្ដើមការងារផងក៏ស្រាប់តែដូចជាមានសម្ពាធទៅហើយ)

- ចុះអ្នកណាគេនិយាយមុននេះឱ្យបងជួយ? អូនស្មាន តែតំណែងមួយនេះ ឬក្រុមហ៊ុនបងចេះតែអញ្ជើញមនុស្សធ្វើ ការក្នុងរយៈពេលមួយម៉ោងពីរម៉ោងលើតុបាយអ៊ីចឹងឬ?

វីរិយ៉ាកាន់តែមានអារម្មណ៍មិនស្រួល ចង់ស្ដាយក្រោយ ដែលលើកសំណើដាក់បញ្ញវន្តមុននេះ ចិត្តមួយ ចង់ហក់តាម អ្វីដែលនាយផ្ដល់ឱ្យ។ សុខៗនាងទៅជាគ្មានជំនឿចិត្តថា

អាចធ្វើបាន ព្រោះតែតំណែង និងមុខនាទីដូចជាធំពេក សម្រាប់ស្រីតូចវ័យ២៥ឆ្នាំម្នាក់នេះ។

អាហារពេលល្ងាចដ៏យូរបានចប់សព្វគ្រប់ អ្នកស្នើនិងអ្នកផ្តល់ជំនួយដូចជាមិនមានអារម្មណ៍រីករាយដូចការណាត់ជួបរាល់ដង។ បន្ទាប់ពីជូនវិរិយ៉ាដល់មុខផ្ទះ បញ្ញវន្តអង្អែលក្បាលនាងកុំឱ្យវិរិយ៉ាទទួលរងសម្ពាធធ្ងន់ពេក៖

- កុំគិតពេកប្រយ័ត្នចាស់អស់លែងស្អាតហើយនាងតូច! បងមិនបង្ខំទេ បងគ្រាន់តែចង់ជួយ ព្រោះឃើញអូនដូចជាមានធុរៈណាស់ អ្វីដែលអាចជួយបាន បងគ្រាន់តែចង់ជួយវិរិយ៉ាណា៎។

វិរិយ៉ាទាញដៃកំពុងអង្អែលក្បាលនាងមកច្របាច់យ៉ាងណែនក្នុងប្រអប់ដៃនាងទាំងពីរ៖

- បងបញ្ញវន្ត! ខ្ញុំពិបាកសម្រេចចិត្តណាស់បង ខ្ញុំទើបតែអាយុ២៥ឆ្នាំទេណា តើអាចធ្វើប្រធានចាត់ការទូទៅបានទេ? ខ្ញុំជំនាញតែទំនាក់ទំនង ហើយក៏មិនធ្លាប់ធ្វើជាប្រធានគេ តើទៅគ្រប់គ្រងគេយ៉ាងម៉េចទៅ? ហើយទៅឆែកការងារផ្នែកដែលខ្ញុំមិនធ្លាប់ធ្វើនោះយ៉ាងម៉េចទៅបង? ខ្ញុំខ្លាចធ្វើមិនល្អ ឱ្យបងពិបាកដោយសារខ្ញុំបង! ខ្ញុំពិបាកចិត្តណាស់

វិរិយ៉ាសម្តែងមុខង៉ិកង៉ក់ដាក់ភ្នែកមួយគូ ដែលសម្លឹងនាងបង្កប់ន័យយ៉ាងជ្រៅ។

- គិតទៅ គិតតាមដំណើរ បើបងដឹងថាស្បែកជើងនោះប្អូនពាក់មិនត្រូវបងមិនជូនប្អូនទេ។

នាងតូចញញឹមចុងក្រោយ ហើយបើកទ្វារឡានចេញទៅ ក្រសែភ្នែកមួយគូដែលតាមសម្លឹងដោយសេចក្តីពេញចិត្ត រហូតនាងតូចបិទទ្វារផ្ទះបាត់ទើបបង្វែរចង្កូតឡានចាកចេញ។

សម្លៀកបំពាក់គេងយប់បែបលក្ខណៈស្តួតទម្លាក់ខ្លួនលើពូកទន់ល្មើយ ដូចជាអស់កម្លាំងខ្លាំងសក់រំសាយគ្របបាត់ខ្នើយដៃគងថ្ងាសភ្នែកសម្លឹងពិដាន យូរៗម្តងស្រីតូចដកដង្ហើមធំរំសាយសម្ពាធ។ សំឡេងសាររបស់វិមន្តតាមទម្លាប់៖

- ព្រះនាងតូច ថ្ងៃនេះទៅដល់ណាខ្លះ?

ឆ្លើយសារទាំងអារម្មណ៍សោះកក្រោះ៖

- គ្រាន់តែនៅផ្ទះរៀនធ្វើគម្រោង និងឆែកការងារបន្តិចបន្តួច។ អំ! ល្ងាចមិញហ្នឹងទៅញុំាបាយជាមួយបងបញ្ញវន្តគ្មានអារម្មណ៍និយាយទេណា ចង់គេងហើយ។

- បានអ៊ីចឹង! គេងចុះណ៎ា! ស្អែកជួបគ្នា។

សារចុងក្រោយសម្រាប់យប់នេះបានបង្ហើរចេញពីទូរសព្ទកំលោះវិមន្តទាំងទឹកមុខសោកសៅ។ ការស្រលាញ់ដែលមានឱ្យវីរិយ៉ាដូចជាអំបិលមួយចឹបបង់ក្នុងទន្លេ ពេលណាទើបនាងធ្វើដឹង? ពេលខ្លះដូចជាឱ្យសង្ឃឹម ពេលខ្លះដូចជាមិនបើក បេះដូង វិមន្តពិបាកចិត្តនឹងទង្វើស្ទាក់ស្ទើររបស់វីរិយ៉ាចំពោះខ្លួន ពេលខ្លះនាយលួចប្រចណ្ឌបញ្ញវន្តដែលមានគ្រប់យ៉ាងហើយទទួលបានការស្ញប់ស្ញែងពីវីរិយ៉ាទៀត។ គិតចុះគិតឡើងក៏ដកដង្ហើមធំ ពិបាកចិត្តពេកមើលឃើញតែវីណាដែលយល់ចិត្តនាយ លើកទូរសព្ទខលទៅនាងជជែកបំបាត់ទុក្ខះ

- សួស្ដីអ្នកកំលោះ! ខលរកកូនក្រមុំគេទាំងយប់មានការអ្វី? (វីណាផ្លែពាក្យឱ្យវិមន្ត)

- ខលទៅឆែកមើលក្រែងលោកូនក្រមុំមួយនេះរវល់និយាយទូរសព្ទជាមួយអ្នកណាហ្នឹងណ៎ា។ (វិមន្តស៊កឱ្យនាងវិញ)

- យើស! ធ្វើដូចហួងហែងម្ល៉េះហ្នឹង? ម៉េចគិតចង់ឱ្យខ្ញុំនៅទំនេររហូតទៅឬអី?

- អត់ទេ! តែបើមានមែនប្រាប់ផងឱ្យខ្ញុំបានជួយអរណ៌ា!

- អ៊ីចឹងកុំអាលអរ ព្រោះមិនទាន់មានផង។

- ហាសហា!

- ចាំអកឱ្យខ្ញុំទៀតហើយ។

- សើចឱ្យអ្នកណាទៀតបើនិយាយគ្នាតែពីរនាក់ហ្នឹង?

- អាងតែខ្ញុំស្លូត! ចាំមើលរៀនធ្វើកាចឱ្យដូចវីរិយ៉ា។

- មិនអាចទេ! វីណាធ្វើយ៉ាងណាក៏មិនដូចដែរ។

- ម៉េចថាមិនដូច? (វីណាសួរភ្លាមៗ)

- វីរិយ៉ានិងវីណាមាននិស្ស័យរៀងខ្លួន ហើយសុទ្ធសឹងតែជាចំណុចល្អនឹងស័ក្តិសមទៅតាមចរិតលក្ខណៈរបស់អ្នកទាំងពីរ។ បើឱ្យវីរិយ៉ាមកធ្វើដូចវីណាក៏គង់ធ្វើមិនដូច ហើយក៏មិនគួរឱ្យស្រលាញ់ដែរ។

- ចង់ថាខ្ញុំមិនគួរឱ្យស្រលាញ់ឬ? (វីណាសួរដូចចង់អន់ចិត្ត)

- អត់ទេ! វីណាមានចរិតសុភាពគួរឱ្យស្រលាញ់ មានទឹកចិត្តត្រជាក់គួរឱ្យចង់នៅក្បែរ (បាត់សំឡេងវីណាឈឹង) បាត់ទៅណាហើយអ្នកនាង? (វិមន្តស្រែករកវីណាតាមទូរសព្ទ)

- នៅហ្នឹង! (វីណាឆ្លើយបន្ទាប់ពីលង់ក្នុងការសរសើរ របស់វិមន្ត)។

- យី! ស្មានតែគេងលក់ហើយតើ!

- ចង់គេងដែរហើយ ខ្ជិលនៅធ្វើចិត្តត្រជាក់ជាក់អ្នកណា អ្នកណីណាស់។

- ចេះធ្វើអ៊ីចឹងទៅកើត! ម៉ោងទើបតែដប់កន្លះសោះ។

- ខ្ញុំខ្លាចអត់ស្អាតណា! ចាស់ហើយត្រូវខំថៃសម្រស់បន្តិច។

- ដឹងខ្លួនចាស់ហើយម៉េចមិនឆាប់បើកបេះដូងទៅ អ៊ីចឹង?

- និយាយស្អីទេ! គេងហើយ! Bye!

វីណាដាក់ទូរសព្ទចុះគេងគិតខុសរឿងតែម្នាក់ឯង។ សុខៗមិត្តល្អទាំងបីលេងល្បែងស្នេហាត្រីកោណពីពេលណា? ភាពស្និទ្ធស្នាលធ្វើឱ្យអ្នកទាំងបីយល់ច្រឡំមិនដឹងមួយណាជាមិត្តភាព មួយណាជាស្នេហា តែមើលទៅឃើញតែវីណា និងវិមន្តទេដែលកំពុងវិលវល់នឹងអារម្មណ៍មួយនេះក្នុងយប់នេះ ចំណែកនាងតូចវីរិយ៉ាដូចជាកំពុងខ្វល់ខ្វាយនឹងរឿងផ្សេងទៅវិញទេ។

ព្រឹកថ្ងៃចន្ទតែងតែជាពេលដ៏រវល់នៅក្នុង Department របស់ Bryant ឃើញវីណាដូចជារវល់ខុសធម្មតានាងរត់ទៅមកទំនាក់ទំនងនឹង Department ដទៃទៀត បន្តិចឃើញចេញចូលក្នុងបន្ទប់របស់ Bryant ដូចជាមានរឿងច្រើនត្រូវពិភាក្សា។

- Bryant! របាយការណ៍មួយនេះនឹងត្រូវសម្រេចឱ្យបាននៅចុងខែនេះហើយ ផ្នែកចាត់ចែងគម្រោងបានសម្រេចជាមួយលោកនាយករួចហើយ មើលទៅក្រុមរបស់យើងនេះទោះជាមិនអាចក៏ត្រូវតែត្រៀមខ្លួនឱ្យបានដែរ។

- មិនថ្វីទេ! ខ្ញុំត្រៀមខ្លួនរួចហើយ។ វីណាសរុបរបាយការណ៍ទាំងអស់នេះទៅ លើកយកនិងបែងចែកគុណសម្បត្តិរបស់ក្រុមការងារយើងរៀងៗខ្លួនទៅណ៎ា។

- ខ្ញុំដឹងហើយ! ធ្វើរួចហើយ ចាំខ្ញុំយកមកជូនលោកពិនិត្យឥឡូវ។

និយាយមិនទាន់ចប់ស្រួលបួលផង នាងដើរចេញពីបន្ទប់ទៅយករបាយការណ៍នោះមកហុចឱ្យ Bryant ។

- នេះ Bryant ! សាកឆែកមើលទៅ វិមន្តនិងវិរិយ៉ាមានចំណុចខ្លាំងរៀងខ្លួន អ្នកទាំងពីរនេះមិនអាចបែងចែកថា

អ្នកណាខ្លាំងជាងអ្នកណាបានសោះ ហើយអ្នកដទៃទៀតបានចំណាត់ថ្នាក់បន្ទាប់ពីពួកគេ។ រីឯខ្ញុំខ្លួនឯងនេះ មិនចេះនិយាយពីខ្លួនឯងទេ ខ្ញុំគ្រាន់តែសរសេរពីអ្វីដែលខ្ញុំបានធ្វើតែប៉ុណ្ណោះ Bryant គួរតែជាអ្នក Commend ឱ្យខ្ញុំទៅ។

- ខ្ញុំមិនមើលរំលងជំនួយការខ្លួនឯងទេ រីណាធ្វើការបានល្អហើយ ខំបន្តទៀតទៅណា។

- អរគុណ Bryant ខ្ញុំមិនបោះបង់ទេ។ (នាងនិយាយដោយស្នាមញញឹមនិងទំនុកចិត្ត)។

- រីណាជួយហៅវីរិយ៉ានិងវិមន្តឱ្យខ្ញុំបន្តិចណា ឱ្យចូលជួបខ្ញុំម្តងម្នាក់ទៅ ព្រោះមានរឿងត្រូវពិភាក្សា។

- ចាស ខ្ញុំដឹងហើយ! (រីណាដើរចេញជាមួយពាក្យឆ្លើយ)

ចេញពីបន្ទប់ Bryant រីណាសម្លឹងមើលមិត្តល្អរបស់នាងទាំងពីរឃើញវិមន្តដូចជាកំពុងរវល់ជាមួយការងារលើកុំព្យូទ័រ ងាកទៅឃើញវីរិយ៉ាអង្គុយដូចគ្មានវិញ្ញាណនាងដើរទៅក្បែរ៖

- អ្នកនាង! ទៅណាហើយវិញ្ញាណ?

វីរិយ៉ាភ្ញាក់នឹងសំឡេង សម្លឹងមុខរីណាដូចមិនទាន់ភ្ញាក់ពីការគិតដ៏វែងឆ្ងាយ។ ធ្វើភ្នែកក្លឹះៗចិញ្ចើមចងដូចជាមានអ្វី

ក្នុងចិត្តតែមិននិយាយ រីណាឆ្ងល់នឹងកាយវិការប្លែករបស់មិត្ត នាងសួរដោយបារម្ភ៖

- ឯងយ៉ាងម៉េចហ្នឹងសម្លាញ់ ?

វីរីយ៉ាមិនប្រែទឹកមុខចម្លែកនេះសោះ មិនស្តីចេះតែសម្លឹងមុខរីណា នាងកាន់តែបារម្ភ កាន់ស្មារីរីយ៉ាអង្រួន។

- នែ៎! យ៉ាងម៉េចហ្នឹង ? ឯងមិនស្រួលខ្លួនឬមានវិបត្តិអ្វី ? វិមន្តមកនេះ! មើលវីរីយ៉ាបន្តិចមើល៎។

នាងស្រែកហៅវិមន្តទាំងដែលនាយកំពុងវល់ជាមួយកុំព្យូទ័រ វិមន្តស្រែកសួរពីតុធ្វើការខ្លួនឯងជាមួយនឹងដំណើរមកកាន់តុរបស់វីរីយ៉ាផង៖

- យ៉ាងម៉េចហ្នឹង ?

វីរីយ៉ាដូចជាភ្ញាក់ពីការគិតមកវិញនាងញញឹមតិចៗ៖

- សុំទោស ខ្ញុំមានរឿងពិបាកសម្រេចចិត្តមួយ ខ្ញុំកំពុងស្មាក់ស្មើរខ្លាំងណាស់ ខ្ញុំដូចជាមិនមានអារម្មណ៍ធ្វើរឿងអ្វីទៀតសោះ។

រីណាអង្អែលដៃវីរីយ៉ាដែលដាក់លើកតុ វិមន្តឈរនៅម្ខាងទៀតអង្អែលក្បាលនាងតូចរបស់នាយ៖

- កុំបារម្ភពេក! វីរិយ៉ានៅមានពួកយើងដែរ និយាយចេញខ្លះមកពួកយើងជួយគិត។

- មែនហើយ! កុំធ្វើដូចទូលភ្នំអ៊ីចឹងណា៎! វាគ្មានស្អីក្រៅពីការងារទេឯងហ្នឹង បើពិបាកអីក៏នៅមានពួកខ្ញុំពីរនាក់ដែរ ហើយបើពិបាកខ្លាំង Bryant អាចជួយបានឯងបាន។

វីរិយ៉ាប្រែទឹកមុខដូចចង់យំនាងក្រោកឈរឱបវីណាយ៉ាងណែនដូចជាការឱបគ្នាលើកចុងក្រោយ មិត្តល្អទាំងពីរកាន់តែឆ្ងល់ពីកាយវិការចម្លែករបស់នាងតូច រិមន្តអង្អែលក្បាលនាងម្តងទៀត។

វីរិយ៉ាដកដង្ហើមធំមួយសិនមុននិយាយទៅមិត្តល្អទាំងពីរ ៖

- បើថ្ងៃមួយខ្ញុំទៅឆ្ងាយទៅ ខ្ញុំនឹងមិនរីករាយដូចពេលនេះទេ បើខ្ញុំមិននៅទីនេះទៀត តើខ្ញុំនៅតែទទួលបានការ Take Care របស់អ្នកទាំងពីរទៀតទេ?

- ទៅណាហ្អាស? ឯងចង់ទៅណា? (វីណាសួរដោយឆ្ងល់)

- ទៅផុតជើងមេឃក៏នៅតែអាចផ្តល់ការ Care ឱ្យវីរិយ៉ាបានដែរ រហូតដល់វីរិយ៉ាលែងត្រូវការវា។ (វិមន្តនិយាយភាសាបេះដូង ដូចចង់បញ្ជាក់អ្វីឱ្យនាងយល់)

ដកដង្ហើមធំមួយទៀតនាងតូចញញឹមៈ

- អរគុណអ្នកទាំងពីរណាស់ បើថ្ងៃមួយខ្ញុំបាត់បង់អ្នកទាំងពីរ ខ្ញុំមុខតែក្លាយជាមនុស្សធំហើយ ហេហេ។

- មិនបាត់ទេ! ពួកយើងមិនទៅណាចោលឯងទេ ក្មេងល្ងង់! មិនដឹងគេមានរឿងស្អីទេ ធ្វើដូចទូលភ្នំមួយម្នាក់ឯង! (វីណាតបក្រោយឃើញស្នាមញញឹមរបស់វីរិយ៉ា)

- ប្រហែលពិបាកចិត្តព្រោះគុណសម្បត្តិឆ្នាំនេះធំធេងជាងគេនៅក្នុងក្រុមហើយទេដឹង? (វិមន្តផ្ញែឱ្យនាងតូចដោយដឹង

ពីស្នាដៃដ៏មហិមារបស់នាង)

- អំមែនហើយ! ឃើញទេ ប៊ិះតែនឹងភ្លេច! Bryant ចាំយូរហើយ អ្នកទាំងពីរនេះ មួយណាក៏បានដែរ ទៅជួប Bryant មុនទៅ។ (វីណានិយាយដោយទឹកមុខត្រេកអរជំនួសមិត្តទាំងពីរ)

- វិមន្តទៅមុនទៅ! ខ្ញុំទៅតាមក្រោយ។

- អត់ទេ! សូមបង្ហើយការងារបន្តិចសិន វីរិយ៉ាដូចជាមិនរវល់ទេ ទៅមុនទៅណា។ (វិមន្តតវ៉ា)

- ថាអត់ទេ! ខ្ញុំឱ្យទៅមុន ទៅៗ។ (វីរិយ៉ាសម្លុត)

- យីនាងតូចនេះ! បាន!បាន!

វិមន្តនិយាយបណ្ដើរដើរទៅតុយកសៀវភៅកត់ត្រាប្រជុំ ហើយដើរសំដៅទៅបន្ទប់ Bryant។ រីណាអង្អែលក្បាលនាងតូចវីរិយ៉ាចុងក្រោយ ហើយដើរទៅតុខ្លួនឯងដើម្បីចាប់បន្តការងារ។ វីរិយ៉ាដកដង្ហើមធំម្ដងទៀតផ្អែកខ្លួនលើកៅអីដូចអស់កម្លាំងពីក្នុងខ្លួន រីណាចេះតែលួចសម្លឹងមើលមិត្តដោយក្ដីបារម្ភ។

នៅក្នុងបន្ទប់របស់ Bryant ដែលមានវិមន្តអង្គុយនៅទល់មុខ អ្នកទាំងពីរពិភាក្សាពីការងារនឹងគម្រោងថ្មីៗសម្រាប់ឆ្នាំក្រោយ៖

- វិមន្ត! កន្លងមកនេះធ្វើការបានល្អណាស់!

- វីរិយ៉ាក៏មិនអន់ដែរ!

- មែនហើយ! ខ្ញុំសំណាងណាស់ដែលបានអ្នកទាំងពីររួមក្រុមជាមួយ ស្នាដៃរបស់វិមន្តនិងវីរិយ៉ាដើរទន្ទឹមគ្នា។

វិមន្តញញឹមទទួលការសរសើរ Bryant ពោលបន្ត៖

- ខ្ញុំជិតផុតកុងត្រាហើយណា! ឆ្នាំក្រោយខ្ញុំនឹងត្រូវទៅប្រទេសបារាំងវិញហើយ។

វិមន្តសម្លឹងមើលមុខ Bryant ដោយទឹកមុខមិនរីករាយ។

- ខ្ញុំមិនចង់គិតថាពេលវេលាទៅមុខឆាប់ដល់ម្លឹងសោះ!

Bryant ដើបដើរទៅទះស្មាវិមន្តថ្នមៗ៖

- នែ! កុំធ្វើដូចស្រីណា! ហាសហា ។

- Bryant ចេះអ៊ីចឹងទៅកើត! ខ្ញុំទុក Bryant ដូចបងប្រុសក្នុងការិយាល័យនេះ ត្រូវតែស្ដាយស្រណោះហើយ។

- មនុស្សយើងត្រូវមានគោលដៅណាវិមន្ត! មិនអាចឱ្យមនោសញ្ចេតនាគ្របដណ្តប់បានទេ!

- នៅអាចជួបគ្នាតែ១ឆ្នាំទៀតទេ។

- មែនហើយ! នៅវាយតម្លៃការងាររបស់វិមន្តបានមួយឆ្នាំទៀតដែរ។

- មិនមែនតែខ្ញុំឯណា Bryant!

- មែនហើយ! មួយឆ្នាំចុងក្រោយនេះវាមុខតែជាពេលវេលាដ៏អស្ចារ្យរបស់ខ្ញុំ។

- មានអ្វីពិសេសមែនទេ Bryant?

- គឺត្រូវមើលការប្រកួតប្រជែងរវាងវិមន្តនិងវីរិយ៉ា។

វិមន្តចងចិញ្ចើមមិនសួរ តែសម្លឹងមើលមុខ Bryant រង់ចាំការរៀបរាប់បន្ត៖

- ត្រូវហើយ! យ៉ាងម៉េចមិនយល់? ព្រោះវិមន្តនិងវិរិយ៉ា មិនមានអ្នកណាខ្លាំងជាងអ្នកណា អ្នកទាំងពីរមានចំណុចអស្ចារ្យរៀងៗខ្លួន ឆ្នាំនេះអ្នកទាំងពីរមានស្នាដៃធំៗដូចគ្នា ខ្ញុំចង់ឱ្យអ្នកទាំងពីរប្រកួតគ្នាយកកៅអីរបស់ខ្ញុំ យ៉ាងម៉េចហ៊ានទេវិមន្ត?

- ប្រកួតជាមួយវិរិយ៉ា? ខ្ញុំមិនធ្វើទេ! ប្រគល់ឱ្យនាងតែម្តងទៅល្អជាង ខ្ញុំមិនចង់យកឈ្នះលើវិរិយ៉ាទេ ហើយក៏មិនដែលគិតថាខ្ញុំខ្លាំងជាងនាងដែរ ទុកកៅអីនេះឱ្យនាងចុះខ្ញុំសូមចុះចាញ់ជាមុន។

- ដូចជាលះបង់ដល់ហើយ! ស្រលាញ់នាងខ្លាំងណាស់មែនទេវិមន្ត?

- យី! ហេតុ ហេតុអ្វី Bryant ដឹង...? (វិមន្តសួរទាំងរដាក់រដុប)។

- ខ្ញុំក៏ជាប្រុសដែរ! ខ្ញុំអាចយល់បាន តែអាណិតខ្លួនទេដែលឱ្យឱកាសទៅគេបានប្រសើរជាងខ្លួន បើបែបនេះធ្វើម៉េចវិរិយ៉ាអាចមើលឃើញវិមន្តបានទៅ?

- ហ៊ឺ! ខ្ញុំមិនយល់ពីចិត្តរបស់វិរិយ៉ាទេ ពេលខ្លះដូចជាមានសង្ឃឹមច្រើន តែពេលខ្លះដូចជាសង្ឃឹមធ្លាក់ដល់ដកសូន្យទៅទៀត ស្រីតូចម្នាក់នេះមិនដឹងថាមានបេះដូងសម្រាប់ការស្រលាញ់ឬអត់នោះទេ ឬក៏នាងមានចិត្តជាមួយនាយកក្រុមហ៊ុនម្នាក់នោះទៅហើយ? (វិមន្តនិយាយទាំងទឹកមុខក្រៀមក្រំ)

ដៃបងប្រុសក្នុងការិយាល័យអង្អែលស្មានាយថ្នមៗម្តងទៀត។

- កុំគិតច្រើន! ស្នេហ៍ក៏មានឧបសគ្គដែរ! បើមិនស៊ូ ធ្វើម៉េចដឹងថាជារបស់យើងឬគេ?

- តែខ្ញុំពិបាកស្មានចិត្តនាងណាស់។ (វិមន្តនិយាយទាំងអស់សង្ឃឹម)

- ចិត្តមិនសឿងតែស្រលាញ់ស្រីចិត្តសឿង! បានហើយកុំចុះចាញ់ទៅធ្វើការវិញសិនទៅណា ហើយហៅវិរិយ៉ាឱ្យជួបខ្ញុំផង។

- បាទ! តែវិរិយ៉ាថ្ងៃនេះនាងមិនសប្បាយចិត្តទេ កុំដាក់សម្ពាធការងារលើចិត្តនាងពេក ថ្ងៃនេះនាងចម្លែកខ្លាំងណាស់។

- ខ្វល់ខ្វាយពេកហើយវិមន្ត! តាំងពីដើមមកដែលឃើញវិរិយ៉ាឱ្យខ្ញុំធ្វើបាបបានទេ? មានតែនាងធ្វើបាបខ្ញុំដែរហ្នឹង។

អ្នកទាំងពីរផ្ទុះសំណើច... វិមន្តដើរចេញពីបន្ទប់Bryant ហៅវិរិយ៉ាចូលជួបប្រធានក្រុម។

ក្នុងបន្ទប់ វិរិយ៉ាអង្គុយចុះដៃច្រត់ចង្កាមើលមុខBryant ធ្វើភ្នែកភ្លឹះៗ ជួននាងយកដៃអេះក្បាល ជួននាងឱនមុខជ្រប់បង្ហាញអារម្មណ៍សោកសៅនិងធុញថប់យ៉ាងខ្លាំង។

តាមសម្លឹងមើលកាយវិការនាងមួយសន្ទុះ Bryant ចាប់ផ្ដើមនិយាយទៅកាន់នាង៖

- ពិតជាដូចវិមន្តនិយាយមែន! នាងតូចថ្ងៃនេះចម្លែកម្ល៉េះ?

ដកដៃពីច្រត់ចង្កាមកកាន់អង្អែលទងត្រចៀកខ្លួនឯង កែវភ្នែកបង្កប់នូវទុក្ខព្រួយសម្លឹងទៅ Bryant ក្នុងន័យអង្វរករ Bryant ពិបាកប្តឹងថ្លែងកាយវិការចម្លែកនេះណាស់ នាយក្រោកពីកៅអីដើរទៅក្បែរវិរិយ៉ា។ ដៃម្ខាងកាន់ស្មា ដៃម្ខាងអង្អែលក្បាលនាងក្នុងកាយវិការលួងលោម។ វិរិយ៉ាអង្គុយលើកៅអីដដែលតែប្រះខ្លួនឱបចង្កេះផ្អែកក្បាលលើខ្លួន Bryant យំខ្សឹកខ្សួលដូចក្មេង។ Bryant កាន់តែឆ្ងល់

លែងសួរគិតតែអង្អែលខ្នងនិងក្បាល ចង់លួងប្អូនស្រីសំណព្វគេឱ្យបានធូរស្រាល។ ខ្សឹកខ្សួលអស់ចិត្ត នាងជូតទឹកភ្នែក ជាមួយទឹកមុខស្លូតស្រពោននិយាយទៅកាន់ Bryant៖

- ខ្ញុំមិនចង់បែកពីអ្នករាល់គ្នាទេ តែខ្ញុំត្រូវដើរទៅរកផ្លូវជោគជ័យរបស់ខ្លួនឯង!

បើកភ្នែកធំៗ ឆ្ងល់នឹងសម្ដីនាងតូចយើង Bryant សួរដោយស្ទាក់ស្ទើរ៖

- នាងតូចចង់ទៅណា? រឺបីរបស់នាងតូចមិននៅទីនេះទេ?

- មែនហើយ! Bryant ខ្ញុំគិតថាខ្ញុំទទួលយកជំនាញនេះបានគ្រាន់បើហើយ ខ្ញុំចង់មានការអភិវឌ្ឍខ្លួនបន្ថែមទៀត ចង់សិក្សាពីជំនាញផ្សេងៗ បើថ្ងៃក្រោយខ្ញុំមានក្រុមហ៊ុនមួយដោយខ្លួនឯង ម្ចាស់ក្រុមហ៊ុនមួយមិនមែនធ្វើការតែជំនាញមួយទេមែនទេ?

- ផ្លូវមួយណាដែលនាងតូចចង់ទៅ? (Bryant យល់សេចក្ដី)

- បងបញ្ញវន្តផ្ដល់ផ្លូវមួយឱ្យខ្ញុំ ឱ្យតំណែងជាអ្នកគ្រប់គ្រងទូទៅនៅក្នុងក្រុមហ៊ុនរបស់គាត់ ឱ្យខ្ញុំហាត់រៀននិងលត់ដំ

ខ្លួនឯងលើជំនាញនោះ ហើយគាត់នឹងជួយពីក្រោយ។ ខ្ញុំមិនទុកចិត្តថាខ្ញុំអាចធ្វើបានឬអត់ទេ Bryant តែខ្ញុំមិនចង់បាត់បង់ឱកាសនិងខាតពេលវេលានោះទេ។ ខ្ញុំចង់ឃើញថ្ងៃជោគជ័យរបស់ខ្លួនឯងឆាប់ៗណាស់។

Bryant សម្លឹងមើលនាងដោយក្រសែភ្នែកស្ងប់ស្ងៀម ដាក់ខ្លួនអង្គុយលើជ្រុងតុ ដៃម្ខាងសង្កត់ក្បាលវីរិយ៉ាងថ្នម។

- មហិច្ឆតាធំ! ឆន្ទៈមោះមុត! មានសមត្ថភាព ហើយក៏មានសំណាងទៀត! ចាប់យកវាឱ្យបានណ៎ា! ខ្ញុំគាំទ្រ! វីរិយ៉ាទៅចុះ! តែត្រូវចាំ! ការបរាជ័យអាចកើតឡើងគ្រប់ពេល បើថ្ងៃមួយវីរិយ៉ាជួបវា កុំទន់ជ្រាយ ហើយឆាប់ត្រឡប់មកវិញ! មកហ្វឹកហាត់ម្តងទៀតណ៎ា!

វីរិយ៉ាស្ទុះក្រោកឈរទាញ Bryant ពីអង្គុយ នាងហក់ឱបក Bryant ដោយក្តីរំភើបនិងរីករាយយ៉ាងខ្លាំង។

- នៅតែជាក្មេងដដែលហ្នឹងស្រីតូច! ទៅធ្វើប្រធានគ្រប់គ្រង
ទូទៅយ៉ាងម៉េចទៅ?

- មានតែនៅទីនេះហើយដែលខ្ញុំអាចធ្វើជាស្រីតូចវីរិយ៉ាបាន បើទៅដល់ទីនោះខ្ញុំនឹងក្លាយជាមនុស្សចាស់ហើយ។

- បាន!បាន!

- Bryant ពិតជាបងប្រុសល្អម្នាក់របស់ខ្ញុំមែន ស្រលាញ់បងប្រុសម្នាក់នេះណាស់។

- ស្រីតូច! ពូកែយកចិត្តណាស់ហ្ន៎!

វីរិយ៉ាសើចគ្រវីខ្លួន Bryant ឈរគ្រវីក្បាលហួសចិត្តនឹងនាង នាយបន្ត៖

- ខ្ញុំគិតថាមួយឆ្នាំចុងក្រោយរបស់ខ្ញុំនឹងបានឃើញកំពូលបុគ្គលិកទាំងពីរនេះប្រយុទ្ធគ្នា តែខកបំណងហើយ។

វីរិយ៉ាបើកភ្នែកធំៗ ៖

- អ្នកណាប្រយុទ្ធនឹងអ្នកណា? មួយឆ្នាំចុងក្រោយមានន័យថាម៉េច?

- កុំធ្វើភ្លេចណ៎ាវីរិយ៉ា! ខ្ញុំមានកុងត្រានៅក្នុងក្រុមហ៊ុននេះតែ៣ឆ្នាំទេ ឆ្នាំក្រោយដល់ពេលដែលខ្ញុំត្រឡប់ទៅបារាំងវិញហើយ។

វីរិយ៉ាស្ទុះឱប Bryant ម្តងទៀតទឹកភ្នែករហាម៖

- ឆាប់ដល់ហើយ!

- កុំយំ! ចាំឆ្នាំក្រោយចាំយំណ៎ា!

Bryant ធ្វើបែបកំប្លែងបន្លប់នាងតូច វីរិយ៉ាដកឃ្លាចេញ
ពី

Bryant បន្តិចនាងសើចបែបអៀន។

- ថ្ងៃនេះជាទិវាថ្ងៃឱប ហាហាហា...។

Bryant ឈរគ្រវីក្បាល។

- គ្រាន់តែជាប្អូនស្រីឱបបងប្រុស ហេតុអីមិនបាន?

ឈរសម្លឹងគ្នាមួយសន្ទុះ Bryant បន្តៈ

- វិមន្តមិនដឹងត្រូវប្រយុទ្ធជាមួយអ្នកណាទេ បើវីរិយ៉ាជ្រើសផ្លូវថ្មីហើយ មើលទៅគេមិនទាន់ដឹងទេមែនទេ?

- នៅទេ! ប៉ុន្តែហេតុអីវិមន្តត្រូវប្រយុទ្ធជាមួយខ្ញុំ? ខ្ញុំដូចមិនយល់សោះ។

- គឺចង់ឱ្យដើងខ្លាំងទាំងពីរប្រកួតគ្នាយកកៅអីខ្ញុំនៅឆ្នាំក្រោយនេះ។

នាងតូចដើរធ្វើឌីទៅអង្គុយកៅអីរបស់Bryant ទះដៃកៅអីពីរបីដងនាងនិយាយយ៉ាងអំនួត។

- កៅអីនេះបើខ្ញុំចង់បានពេលណាក៏បាន! ហេតុអីត្រូវប្រកួតជាមួយវិមន្តដល់ទៅមួយឆ្នាំ? ខ្ញុំចាំបានកាលកៅអី

ចាស់របស់ Bryant ខូច ខ្ញុំបានទៅជាមួយបងផ្នែករៀបចំសម្ភារៈការិយាល័យ ទៅទិញវាមក ខ្ញុំស្គាល់កន្លែងលក់អ៊ីតើ!

Bryant សើចហួសចិត្តនឹងពាក្យសម្ដីហូរដូចទឹករបស់នាងតូចឆ្មើមម្នាក់នេះ៖

- បានហើយ ចុះពីកៅអីខ្ញុំភ្លាមនាងតូច! កុំអង្គុយកៅអីចាស់មួយនេះអី! កៅអីថ្មីជាប្រធានគ្រប់គ្រងផ្នែកទូទៅវាសង្ហាជាងនេះឆ្ងាយណាស់! (នាយឌឺឱ្យស្រីតូច)

នាងតូចនឹកឃើញដល់រឿងចាកចេញម្ដងទៀត ប្រែទឹកមុខ Bryant អង្អែលក្បាល នាយបន្ត៖

- កុំលាក់នឹងមិត្តល្អរហូតដល់ថ្ងៃចាកចេញអី ឆាប់ទៅប្រាប់ពួកគេឱ្យដឹងកុំឱ្យគេអន់ចិត្ត។

- តែខ្ញុំមិនដាច់ចិត្តសោះ។

- គ្មានការជួបដែលមិនបែកនោះទេ! បើវីរិយ៉ាមិនចេញពីខ្ញុំ ក៏ឆ្នាំក្រោយនេះ ខ្ញុំនឹងចេញពីវីរិយ៉ាដូចគ្នា ឃើញទេ?

- មែនហ្នឹង! តែពួកគេទាំងពីរ?

- ព្រោះពួកគេមិនទាន់មានជម្រើសល្អជាងនេះដូចនាង។

- ខ្ញុំស្ដាយមិត្តភាពនៅទីនេះណាស់ មិនដឹងចេញទៅអាច

រកបានមិត្តឯណាល្អជាងនេះទៀតទេ មិនអាចមានប្រធានដែលមានទឹកចិត្តដូចជាបងប្រុសដូច Bryant ទៀតនោះទេ។

- ត្រូវហើយ! ព្រោះនាងក្លាយជាប្រធានគេទៅហើយ! ចាំណាំត្រូវស្រលាញ់បុគ្គលិកក្រោមបង្គាប់ឱ្យដូចជាប្អូន ត្រូវចេះការពារ ជួយ និងឱ្យដំបូន្មានគេ។

- អរគុណបងប្រុស! (វីរិយ៉ាឱប Bryant ម្តងទៀតមុនដើរចេញទៅ)

ចេញពីក្នុងបន្ទប់របស់ Bryant ជាមួយនឹងទឹកមុខមិនរីករាយ មានមិត្តទាំងពីររបស់នាងកំពុងឈរសម្លឹងនាងពីតុរបស់វីណា។

នាងតូចឈរសម្លឹងតបក្រសៃភ្នែកធ្ងល់ និងព្រួយបារម្ភពីមាត់ទ្វារបន្ទប់របស់ Bryant មួយសន្ទុះ វីរិយ៉ានិយាយទៅកាន់មិត្តដោយសំឡេងខ្សោះៗ ៖

- ថ្ងៃនេះពួកយើងទៅញ៉ាំបាយថ្ងៃត្រង់ជាមួយគ្នាណ៎ា។

មិត្តទាំងពីរមិនឆ្លើយគ្រាន់តែសម្លេងកែវភ្នែកទទួលសំណើកាយវិការប្លែកៗរបស់វីរិយ៉ាធ្វើឱ្យមិត្តនាងមិនអាចប្រមូលអារម្មណ៍ធ្វើការបានទៀតទេ តិចៗវីណាដកភ្នែកពី

កុំព្យូទ័រសម្លឹងមកនាងតូចក្នុងន័យបារម្ភ។ វិមន្តដាក់ការងារចុះអង្គុយសម្លឹងតែវិរីយ៉ា ពិតជាមិនយល់តើនាងកើតអីមួយសន្ទុះនាយដើរទៅធុងកាហ្វេក្តៅមួយកែវយកមកហុចឱ្យស្រីតូច៖

- ញ៉ាំកាហ្វេក្តៅមួយកែវទៅ។

វិរីយ៉ាសម្លឹងមុខនាយ ដៃទទួលកាហ្វេយកមកក្រេបបន្តិចហើយសម្លឹងមុខវិមន្តបន្តដោយកែវភ្នែកដែលគ្មាននរណាយល់ពីនាង វិមន្តតឹងទ្រូងនឹងកាយវិការចម្លែករបស់វិរីយ៉ាជាពន់ពេក នាយគិតក្នុងចិត្តឬមួយវិរីយ៉ាបារម្ភការប្រកួតគ្នាយកកៅអីរបស់ Bryant? តែមុនជួប Bryant នាងក៏ចម្លែកស្រាប់ទៅហើយ មិនយល់ថានាងកំពុងគិតអី វិមន្តគ្រាន់តែអង្អែលក្បាលស្រីតូចហើយក៏ដើរទៅអង្គុយនៅតុរបស់ខ្លួនវិញ។

ដល់ម៉ោងចេញទៅញ៉ាំបាយរីណានិងវិមន្តអង្គុយមើលមុខគ្នា ក្រសែភ្នែកតឿនគ្នាទៅវិញទៅមក ឱ្យទៅដាស់វិរីយ៉ាពីការគិតដ៏វែងអន្លាយរបស់នាង។

រីណាយួរកាបូបដើរទៅតុវិរីយ៉ា ម្រាមដៃស្រឡូនគោះតុតិចៗ៖

- វិរីយ៉ា! តស់ញ៉ាំបាយ។ (រីណា)

-ភ្ញាក់ដូចគេដាស់ ដល់ម៉ោងញុំាបាយហើយ? លឿនម្ល៉េះ? មិនទាន់បានធ្វើអីផង។ (វីរិយ៉ា)

សំណើចហួសចិត្តតិចៗរបស់វិមន្តជាមួយសម្រឹបជើងដើរមកតុនាង។

- មួយព្រឹកនេះវល់យកវិញ្ញាណទៅណា ហើយមករអ៊ូម៉ោងដើរលឿន ដល់ហើយណ៎ានាងតូច! តស់រៀបចំទៅយើងឆាប់មកវិញ។

និយាយចប់ស្របពេលវីរិយ៉ារៀបចំរួចល្មម។ មិត្តទាំងបីបណ្តើរគ្នាចេញពីកន្លែងធ្វើការ សំដៅទៅភោជនីយដ្ឋានជប៉ុនលំដាប់ល្មម។ ពេលទៅដល់ វីណាបើកសៀវភៅកុម្ម៉ង់ម្ហូបសម្រាប់បីនាក់ វីរិយ៉ាលើកតែត្រជាក់មកក្រេប រួចសម្លឹងឆ្វេងស្តាំ។

- ខ្ញុំដូចមិនធ្លាប់មកទីនេះសោះ? អ្នកទាំងពីរដូចស្គាល់ទីនេះច្បាស់ម្ល៉េះ?

វិមន្តដាក់កែវទឹកចុះពីដៃសម្លឹងទៅវីណាបន្តិច រួចងាកទៅឆ្លើយនឹងវីរិយ៉ា៖

- បានអីធ្លាប់បើអ្នកនាងតូចមិនសូវមានពេលឱ្យពួកយើងផង ថ្មីៗនេះរវល់តែរហូតហ្នឹង ពេលខ្លះឮថាទៅញ៉ាំបាយជាមួយលោកនាយកក្រុមហ៊ុនឯណានោះ។ (វិមន្តផ្លែផ្កាឱ្យវិរិយ៉ាបង្ហាញភាពប្រចណ្ឌ)

- មែនហើយវិរិយ៉ា ឯងកើតអីព្រឹកមិញហ្នឹង? ដឹងទេពួកយើងគ្មានអារម្មណ៍ធ្វើការសោះ ខ្វល់ពីឯងណាស់។

ចប់សំណួរវីណាទាញកែវទឹកតែយកមកក្រេបផ្សើមបំពង់ក វិរិយ៉ាប្រែទឹកមុខសម្លឹងទៅវិមន្ត។

- លោកនាយកក្រុមហ៊ុនយ៉ាងម៉េច? ប្រាប់ហើយថាគាត់ឈ្មោះបញ្ញវន្ត ហៅគាត់ថាបងបញ្ញវន្តដែរទៅ ព្រោះគាត់ប្រហែលអាយុលើសវិមន្តពីរបីឆ្នាំដែរ ណាមួយបទពិសោធនិងសមត្ថភាពគាត់សមជាសិស្សច្បងវិមន្តហើយ។

វិមន្តដាក់ទឹកមុខចុះ លើកកែវតែក្រេបបន្លប់ការចាប់អារម្មណ៍វិរិយ៉ាបន្តជាមួយនឹងភ្នែករវេទៅវីណា៖

- បងបញ្ញវន្តបានឱ្យឱកាសធំមួយមកខ្ញុំដើម្បីសម្រេចក្តីប្រាថ្នាថ្ងៃនៅអនាគតរបស់ខ្ញុំ។

ដៃរីណាឱបកែវតែជាប់មិនលែង សម្លឹងវីរិយ៉ាមិនដាក់ភ្នែក តាមចាប់អារម្មណ៍គ្រប់សម្ដីដែលមិត្តនាងនិយាយ វីរិយ៉ារេភ្នែកសម្លឹងទៅវិមន្ត ហើយនាងពោលបន្ទះ

- ខ្ញុំបានសម្រេចចិត្តរួចហើយ ខ្ញុំនឹងលាឈប់ពីក្រុមហ៊ុនមួយនេះហើយទៅធ្វើការជាមួយបងបញ្ញវន្ត។

ភ្នែកទាំងបួនបើកធំៗសម្លឹងទាំងតក់ស្លុតៈ

- ហេតុអីវីរិយ៉ា? (ជាសំឡេងដ៏កម្សត់របស់វិមន្ត)

- ឯងគិតច្បាស់ហើយឬសម្លាញ់?

រីណាសួរនិងស្រវាទៅចាប់ដៃនាងតូចវីរិយ៉ាប្រចាច់យ៉ាងណែន វីរិយ៉ាប្រើមុខមាំបន្តឆ្លើយៈ

- ខ្ញុំមិនចង់បាត់បង់ឱកាសនោះទេ! ខ្ញុំមិនចង់ទទួលយកបទពិសោធតែមួយផ្នែកបែបនេះទេ អនាគតរបស់ខ្ញុំមិនមែនគ្រាន់តែជាអ្នកជំនាញផ្នែកទំនាក់ទំនងបែបនេះទេ ខ្ញុំត្រូវធ្វើជាស្ត្រីដ៏ជោគជ័យក្នុងមុខជំនួញ។

វិមន្តដកដង្ហើមធំ ភ្នែកប្រែស្រអាប់សម្លឹងមើលទឹកមុខមហិមារបស់ស្រីតូចដែលខ្លួនស្រលាញ់ រីណាបានត្រឹមតែចងចិញ្ចើមមិនរីករាយនឹងដំណឹងមួយនេះ។

អាហារលើកមកដល់រៀបចំដាក់ពេញតុ អ្នកទាំងបីអង្គុយសម្លក់មួយសន្ទុះវីរីយ៉ាកាន់ចង្កឹះចាប់ស៊ូស៊ីមួយដុំដាក់ឱ្យវីណា៖

- ឯងញ៉ាំទៅ! មិនធ្វើការជាមួយគ្នាក៏ថ្ងៃក្រោយអាចញ៉ាំបាយជាមួយគ្នាបានដូចពេលនេះអ៊ីចឹង។

សម្លឹងមើលមុខអ្នកកំលោះបន្តិច នាងចាប់ត្រីសាលម៉ុនមួយដុំដាក់ចានវិមន្ត ៖

- នែ! វិមន្តចូលចិត្តមួយនេះ ថ្ងៃក្រោយមកហាងនេះទៀតកុំភ្លេចហៅខ្ញុំផងណា។

វីណាចាប់ស៊ូស៊ីមួយដុំនោះឡើងនិងនិយាយបណ្តើរ។

- ឯងហ្នឹងអី មានពេលមកញ៉ាំបាយជាមួយពួកខ្ញុំ? រាល់ថ្ងៃធ្វើការជាមួយគ្នាបានត្រឹមតែឃើញមុខពេលព្រឹកមួយភ្លែតហើយក៏បាត់ស្រមោល។

និយាយចប់នាងលើកស៊ូស៊ីដាក់ចូលក្នុងមាត់ញ៉ាំ។

- វីរីយ៉ាចិត្តដាច់ណាស់ ខ្ញុំដូចជាមានអារម្មណ៍ថានេះជាអាហារលាគ្នាយ៉ាងម៉េចទេ។

វិមន្តនិយាយបណ្តើរលើកសាលម៉ុនញ៉ាំបណ្តើរ។

- ថ្ងៃសៅរ៍ ថ្ងៃអាទិត្យមិនធ្វើការក៏អាចជួបគ្នាបានទេតើ យើងអាចទៅហាត់ប្រាណ ទៅហាងកាហ្វេអានសៀវភៅ ឬ យើងទៅលេងតាមភ្នំ ថ្ងៃបុណ្យឈប់សម្រាក យើងទៅសមុទ្រ ដូចកាលមុនទៀត ខ្ញុំចូលចិត្តរូបថតដែលវិមន្តផ្ដិតឱ្យ ស្រលាញ់ស៊ុមដែលរីណាដាក់ឱ្យ ឃើញទេវាតែងតែនៅលើតុ ធ្វើការរបស់ខ្ញុំ។

វីរិយ៉ាព្យាយាមបន្ធូរភាពតានតឹងក្នុងចិត្តរបស់មិត្តនាង ទាំងពីរ។

- បានហើយនាងតូច! ថ្ងៃសៅរ៍អាទិត្យ ថ្ងៃបុណ្យស្អីទៅ! អ្នកនាងមិនដែលទំនេរទេ។

វិមន្តនិយាយបណ្ដើរចាប់ម្ហូបដាក់ចានវីរិយ៉ាបណ្ដើរ។

- មែនហើយ! ការងារឯងមិនដែលទំនេរសោះ បើឯង ទៅ មិនដឹងធ្វើម៉េចអាចជួបមុខឯងបានទេ។

រីណានិយាយស្របពេលហុចចានទទួលបង្គាបំពងពី វិមន្ត វីរិយ៉ាលើកទឹកក្រេបបន្តិច នាងបន្តជាមួយមិត្តទាំងពីរះ

- ព្រោះខ្ញុំតែងគិតថាពួកយើងជួបគ្នារាល់ថ្ងៃហើយ ទើប ថ្ងៃសម្រាកម្ដងៗចេះតែចង់ធ្វើការដែលមិនទាន់បានធ្វើ ថ្ងៃ

ក្រោយទៅខ្ញុំនឹងរកពេលវេលាជួបទាំងពីរនាក់ហ្នឹងឱ្យបាន ច្រើនបានទេ?

វីណាចាប់បន្លែមួយដុំដាក់ចានវីរិយ៉ា៖

- ខ្ញុំសង្ឃឹមថាឯងមិនទៅទាំងចិត្តទៅចុះ ពួកយើងជូនពរ ឯងឡើងកាំជណ្តើរបានមួយកាំទៀតណ៎ា។

វិមន្តដាក់ស្លាបព្រាចុះលើចាន នាយបន្តសម្តីវីណា៖

- បើពិបាកកុំខំពេកណាវីរិយ៉ា! មនុស្សដែលកាន់តែ ជោគជ័យ សម្ពាធក៏កាន់តែធំដែរ។

ទទួលចានបង្អែមពីអ្នកបម្រើក្នុងហាង វីរិយ៉ាឆ្លើយទៅវិម ន្ត៖

- ខ្ញុំមិនទន់ខ្សោយទេវិមន្ត ខ្ញុំនឹងតស៊ូ។

វីណាសម្តែងការបារម្ភ នាងសម្លឹងមុខវីរិយ៉ាតបប្រយោគ៖

- តែបើឯងពិបាកខ្លាំងកុំស៊ូពេកវីរិយ៉ា! មនុស្សប្រើពេល មួយជីវិតដូចគ្នា តែដើរលើផ្លូវមិនដូចគ្នាទេ មនុស្សស្រីដែល ជោគជ័យគឺមហិមាណាស់ តែមិនមែនទាល់តែក្លាយជា ស្តេចស្រីទើបជោគជ័យនោះទេ។

- សុភមង្គលរបស់ឯងគឺបានរស់នៅជាមួយមនុស្សដែល ឯងស្រលាញ់ ឯងទន់ភ្លន់ណាស់វីណា ឯងសមជាប្រពន្ធ

ឯងសមជាអ្នកម៉ាក់។ តែខ្ញុំមិនដូចឯងទេ ខ្ញុំចង់ប្រើពេលមួយជីវិតដើម្បីជោគជ័យមួយនោះ! ខ្ញុំនឹងក្លាយជាស្ត្រីដែលជោគជ័យក្នុងមុខជំនួញ! ខ្ញុំនឹងធ្វើវាឱ្យបាន មិនថាផ្លូវមួយនោះពិបាកយ៉ាងណាទេ។

វីរិយ៉ាជួសបង្អែមញ៉ាំដោយទឹកមុខមោះមុត ដូចជាកំពុងតែសន្យានឹងខ្លួនឯង វិមន្តស្តាប់ពាក្យទាំងនេះហើយទទួលអារម្មណ៍ឈឺផ្សាក្នុងទ្រូង ដាក់កែវតែចុះ ពោលទៅរីណា៖

- រីណា! វីរិយ៉ាមិនមែនជាមនុស្សស្រីធម្មតាទេ បេះដូងនាងបានប្រគល់ឱ្យសមុទ្រទៅហើយ នាងមានតែខួរក្បាលមួយសម្រាប់គិតរឿងការងារប៉ុណ្ណោះ។

វីរិយ៉ាបើកភ្នែកធំៗសម្លឹងវិមន្តដោយឆ្ងល់នឹងពាក្យបញ្ចើរបស់នាយ រីណាសើចស្ងួតស្រដីបន្ត៖

- រិះតែភ្លេច! អរគុណវិមន្តបានរម្លឹក ឈប់ឆ្ងល់ទៅវីរិយ៉ានេះជាការពិតរបស់ឯងហើយ។

នាងតូចបានតែធ្វើភ្នែកម៉ក់ៗមិនយល់ពីអ្វីដែលមិត្តគេនិយាយ។ អាហារថ្ងៃត្រង់ដ៏ជូរចត់របស់មិត្តទាំងបីបានបញ្ចប់ឡានបរមកដល់ការិយាល័យវិញ ម្នាក់ៗសង្វាតការងាររៀង

ខ្លួនព្រោះតែកិច្ចការពីព្រឹកមិនបានបំពេញរួចរាល់ អ្នកទាំងបី
មិនមាននរណាបង្ហាញទឹកមុខរីករាយឡើយ។



- នេសា! ល្ងាចនេះត្រូវធ្វើរបាយការណ៍មួយនេះឱ្យហើយឱ្យខ្ញុំ ខ្ញុំត្រូវការឆែកមើលខ្ទង់ចំណាយខែនេះ។ ឡូរ៉ាក៏អ៊ីចឹងដែរ! យកបញ្ជីបុគ្គលិកចាស់និងថ្មីឱ្យខ្ញុំ បែងចែកឱ្យបានច្បាស់ ចំនួនបុគ្គលិកដែលលាឈប់ទៅ និងបុគ្គលិកដែលទើបចូលថ្មី។
- បងស្រីប្រធាន! នេះជាសំណើសុំផ្សព្វផ្សាយ Promotion នៅលើកាសែត។

# បរិយាកាសថ្មី

នៅក្នុងតុប្រជុំឮតែសំឡេងជជែកផ្លាស់ប្តូរយោបល់គ្នាយ៉ាងសកម្មៈ

- នេសា! ល្ងាចនេះត្រូវធ្វើរបាយការណ៍មួយនេះឱ្យហើយឱ្យខ្ញុំ ខ្ញុំត្រូវការឆែកមើលខ្ទង់ចំណាយខែនេះ។ ឡូរ៉ាក៏អ៊ីចឹងដែរ! យកបញ្ជីបុគ្គលិកចាស់និងថ្មីឱ្យខ្ញុំ បែងចែកឱ្យបានច្បាស់ចំនួនបុគ្គលិកដែលលាឈប់ទៅ និងបុគ្គលិកដែលទើបចូលថ្មី។

- បងស្រីប្រធាន! នេះជាសំណើសុំផ្សព្វផ្សាយ Promotion នៅលើកាសែត។

បុព្វជាប្រធានផ្នែកផ្សព្វផ្សាយប្រចាំក្រុមហ៊ុន និយាយនិងហុចឯកសារយ៉ាងគួរសមទៅវិរិយ៉ា។

- បុព្វេ! កាសែតមួយនេះមិនសមផ្សព្វផ្សាយផលិតផលក្រុមហ៊ុនរបស់យើងទេ។ យើងលក់គ្រឿងសង្ហារិម ហើយម៉ាកដែលយើងលក់ជាម៉ាកល្បី អ្នកដែលប្រើប្រាស់សង្ហារិមទាំងនេះ មិនមែនជាអ្នកអានកាសែតនេះទេ ទោះក្រុមហ៊ុនកាសែតនេះយកតម្លៃទាបក៏ពិតមែន តែវាមិនមានតម្លៃឱ្យយើងចំណាយលុយទាំងនេះទេ យើងអាចចំណាយខ្ពង់ច្រើនជាងនេះតែត្រូវចំណាយឱ្យចំទីផ្សារ។ អរគុណបុព្វេដែលជួយសន្សំសំចៃឱ្យក្រុមហ៊ុនយើង, បងរីករាយណាស់។

- បាទបង!

ប្រធានផ្នែកផ្សព្វផ្សាយទទួលយកឯកសារពីអ្នកបងប្រធានវីរិយ៉ាវិញដោយក្តីគោរព ការប្រជុំចប់សព្វគ្រប់វីរិយ៉ារៀបចំប្រមូលឯកសារចូលធ្វើការក្នុងការិយាល័យផ្ទាល់ខ្លួនរបស់នាងវិញ។

សម្រឹបជើងមួយគូដើរចូលមកដោយមិនគោះទ្វារ អ្នកបងប្រធានមុខមាំសម្លឹងមើលអ្នកដើរ យើញហើយក៏ប្តូរទៅជាញញឹមវិញ៖

- សំណាងហើយ បើខ្ញុំមិនមែនជានាយកក្រុមហ៊ុនមួយនេះ ម្ល៉េះត្រូវមាត់បងស្រីប្រធានហើយ!

លោកនាយកបញ្ញាវន្ត និយាយបណ្តើរ ដើរបណ្តើរសំដៅតុធ្វើការរបស់វីរិយ៉ា៖

- បងបញ្ញាវន្តមកវិញលឿនម្ល៉េះ? ក្រែងថាប្រជុំដល់ចុងអាទិត្យនោះអី?

- នឹកអូនពេក ទើបឆាប់មកវិញ។ (លោកនាយកនិយាយបែបខិល)

- នឹកខ្ញុំឬនឹកបញ្ជីស្នាម? នេះមកជួយឆែកគ្នាក៏បានដែរច្រើនណាស់បង! ធ្វើមិនចេះចប់សោះ។

នៅចំពោះមុខអ្នកកំលោះ វីរិយ៉ាក្លាយជានាងតូចពូកែរំអួយវិញមួយប៉ប្រិចភ្នែក។

- យើ! ហ៊ានរំអួយផងឬ! តិចបុគ្គលិកក្រោមបង្គាប់ឃើញនឹងខ្មាសគេមិនខាន។ (បញ្ញាវន្តញ៉ោះឱ្យនាង)

- បងបញ្ញាវន្តនេះ! ឱ្យខ្ញុំសុំធ្វើជាខ្ញុំមួយភ្លែតបានទេ?

វីរិយ៉ាសម្តែងភាពង៉ក់ងរចង់បានការលួងលោម បញ្ញាវន្តដើរទៅជិតអង្អែលក្បាលនាងតូច។

- អាណិតដល់ហើយនាងតូចរបស់បង។

វីរិយ៉ាមិនព្រមឈប់ង៉ក់ងរទម្លាក់ឯកសារមួយដុំឱ្យទៅលោកនាយកដោយមិនខ្លាចចិត្ត។

- នេះ! មិនបាច់អាណិតទេ ឆែកហើយកុំតែបន្ទោសទៅបានហើយ ព្រោះខ្ញុំកែទ្រង់ទ្រាយមួយចំនួន មិនដឹងបងពិបាកមើលឬអត់ទេ។

- វិរិយ៉ាមិនដែលកែពីល្អទៅអាក្រក់ទេ! បងធ្វើការជាមួយប្អូនជិតមួយឆ្នាំហើយ វិរិយ៉ាជួយក្រុមហ៊ុនបានច្រើនណាស់ សំណាងហើយដែលវិរិយ៉ាព្រមមកធ្វើការជាមួយ។

បញ្ញវន្តនិយាយទាំងទទួលយកឯកសារពីដៃនាងតូច ខ្សែភ្នែកដឹងគុណសម្លឹងទៅបញ្ញវន្តៈ

- មានតែខ្ញុំអរគុណបងទៅវិញទេ ដែលផ្ដល់ឱកាសមួយនេះឱ្យខ្ញុំ បើមិនអ៊ីចឹង មិនដឹងថ្ងៃណាចេះបានប៉ុណ្ណេះទេ។

- ចុះពេលនេះមានលួចធុញការងារទាំងនេះឬនៅ? បងខ្លាចតែសុខៗវិរិយ៉ាទៅចោលបងទេ!

- មិនទាន់ទៅទេបង! នៅមានច្រើនទៀតត្រូវរៀនពីបង។

- អ៊ីចឹងគង់តែទៅទេ?

- ត្រូវហើយ! បងកុំធ្វើដូចមិនដឹង! គោលបំណងខ្ញុំមិនមែនត្រឹមនេះទេ!

- បងដឹងហើយ! មិនចង់បាត់បង់វិរិយ៉ាទេ តែសង្ឃឹមថាអូនឆាប់ដើរដល់គោលដៅដែលអូនចង់បាន។

- អរគុណហើយបង!

- វីរិយ៉ា! ថ្ងៃនេះញ៉ាំបាយជាមួយបងណា។

- អត់ទេ! ខ្ញុំរវល់ហើយ។

- រវល់ជាមួយអតិថិជនណាដែរ? ឱ្យបងចូលរួមបានទេ?

- យកតំណែងលោកនាយកមកប្រើភ្លាមហ្ន៎!

- បើមិនអ៊ីចឹងមិនដឹងពេលណាបានញ៉ាំបាយជាមួយបងស្រីប្រធានទេ?

អ្នកទាំងពីរសើចធ្វើមុខឱដាក់គ្នាបង្ហាញកាយវិការមិនខ្លាចចិត្តគ្នាសោះ វីរិយ៉ាតាំងតែពីចូលរួមការងារជាមួយបញ្ញវន្ត អ្នកទាំងពីរកាន់តែមានភាពស្និទ្ធស្នាល តែ... តើវីរិយ៉ានៅតែផ្ញើបេះដូងនៅសមុទ្រឬយ៉ាងណា? ចុះវិមន្តនិងរីណាមិត្តល្អរបស់នាងតើពួកគេយ៉ាងដែរ?

យប់ដែលពោរពេញទៅដោយសន្សើមធ្លាក់ វិមន្តដើរចុះឡើងក្នុងសួនច្បារក្រោមផ្ទះនិយាយទូរសព្ទសើចកក្អឹកជាមួយរីណា៖

- កុំឱពេក! ចាំមើលតែស្អែកដឹងគ្នាហើយយើង!

- មិនខ្លាចទេ! បើពូកែធ្វើមែនទៅកុំបានតែសម្ដី!

- ចាំមើលទៅដឹងហើយ! មិនទិញអាហារពេលព្រឹកឱ្យញ៉ាំទេ!

- ឱ្យតែចិត្តដាច់ ខ្ញុំឃ្លានឱ្យមើល!

- ហាសហា ស្មានតែពូកែ!

- ពូកែហើយហ្នឹង!

- វីណាឥឡូវស្នងតំណែងវីរីយ៉ាហើយ។

- កុំនិយាយពីនាងតូចនោះអី! មុនទៅសន្យាបានណាស់តាំងពីទៅបាត់ជួបមិនបានដប់ដងផង។

- គេរវល់ណា!

- មែនហើយ ព្រោះគេរវល់ទើបរិមន្តមានពេលនិយាយជាមួយខ្ញុំ។ (វីណាសម្តែងភាពងរង៉ក់)

- ហាសហា ចេះងរង៉ក់អ្វីហ្នឹង?

- ខ្ញុំងរ មិនលួងខ្ញុំទេ បើនាងតូចនោះវិញតាមលួងនោះ!

- អីយ៉ា! អ្នកនាងវីណាឥឡូវចេះច្រណែនហើយ។

- បើមិនអ៊ីចឹងមិនបាន Care ខ្លះទេ។

- ហាសហាបាន! បាន! ក្លាយជាព្រះនាងតូចម្នាក់ទៀតហើយ។

អ្នកទាំងពីរសើចកក្អឹក វីណារម្លឹកះ

- ហ្អែរិមន្ត! រីរីយ៉ាប្រហែលភ្លេចថ្ងៃជប់លៀងជូនដំណើរ Bryant ហើយ!

- ប្រហែលហើយ! រីណារម្លឹកនាងទៅ។

- អត់ទេ! រិមន្តឯងទៅ!

- យី! បាន! បាន! ខ្ញុំក៏បាន!

ការសន្ទនាជាមួយព្រះនាងរីណាបានបញ្ចប់ រិមន្តដើរចុះឡើងសញ្ជឹងគិត។ បើcall ទៅតើនាងតូចនោះទំនេរនិយាយជាមួយខ្ញុំទេ? គិតម្នាក់ឯងបន្តិច នាយក៏ call ទៅនាងតូច
រីរីយ៉ារបស់គេ៖

- រិមន្ត! សំណព្វចិត្ត! នឹកណាស់។ (រីរីយ៉ានិយាយបែបរលោម)

- បានហើយ! តែប៉ុណ្ណឹងចង់បន្ទោសអ្វីក៏លែងចង់វិញដែរ ពូកែណាស់អ្នកនាង។

- ខ្ញុំលែងក្លាយជាព្រះនាងហើយ?

- ទៀតហើយ! ម៉េចហ្នឹង? ថ្ងៃហ្នឹងម្នាក់ៗចង់ក្លាយជាព្រះនាងម្ល៉េះ? ទើបតែដាក់ទូរសព្ទពីព្រះនាងរីណាចុះអម្បាញ់មិញទេណា។

- និយាយគ្នារាល់ថ្ងៃ? (វីរិយ៉ាប្រើសំឡេងអន់ចិត្ត)

- មែនហើយ! និយាយរាល់តែថ្ងៃហ្នឹង ហើយក៏និយាយដើមវីរិយ៉ារាល់ថ្ងៃដែរ។

វិមន្តឆ្លើយទាំងមិនបានចាប់អារម្មណ៍សំឡេងអន់ចិត្តរបស់នាងតូច វីរិយ៉ាលែងស្តីបន្តនៅតែស្ងៀម វិមន្តហៅរកនាង ៖

- វីរិយ៉ាទៅឯណាហើយ! រវល់ទៀតហើយឬអីអ្នកនាង?

- មិនរវល់ទេ! ទោះរវល់ក៏គ្មានអ្នកណាខ្វល់ដែរ មានអ្នកកំដរហើយ ម្នាក់ៗក៏ភ្លេចខ្ញុំអស់ដែរ។

វីរិយ៉ាបង្ហាញភាពង៉ក់ងរ វិមន្តហាក់យល់ន័យ នាយព្យាយាមស្ទង់ចិត្តវីរិយ៉ា៖

- វីរិយ៉ា! បែកគ្នាយូរណាស់ហើយណា! នៅទីនោះពិបាកណាស់មែនទេបានជាវីរិយ៉ាកាន់តែគ្មានពេលសោះ។

- រវល់ណាស់! តែក៏សប្បាយនឹងការងារដែរ ខ្ញុំពេញចិត្តនឹងអ្វីដែលខ្ញុំធ្វើរាល់ថ្ងៃនេះណាស់ មានអារម្មណ៍ថាប្រកបដោយក្តីសង្ឃឹម!

- វីរិយ៉ាពេលណាទើបបើកបេះដូងទៅ បើគិតតែរឿងការងារយ៉ាងនេះ?

- វិមន្ត! ម៉េចបានសុខៗចេះតែសួរដដែលៗអ៊ីចឹង?

- ខ្ញុំអន្ទះសាណាស់វីរិយ៉ា! តើខ្ញុំមិនសមនឹងវីរិយ៉ាឬវីរិយ៉ាបើកចិត្តឱ្យអ្នកផ្សេងហើយ? (វិមន្តសួរទាំងសំឡេងអស់សង្ឃឹម)។

- ចិត្តខ្ញុំគ្មានអ្នកណាទេវិមន្ត ប៉ុន្តែខ្ញុំមិនអាចបែងចែកពេលវេលាបានទេ បំណងប្រាថ្នាខ្ញុំគឺសំខាន់ជាងអ្វីទាំងអស់។ (វីរិយ៉ាតបទាំងចិត្តដាច់)

- ហ៊ឺ! អ៊ីចឹងវីរិយ៉ាគេងចុះ យប់ជ្រៅហើយ ខ្ញុំក៏ងងុយណាស់ដែរ។

- ចាំ!

វីរិយ៉ាដឹងថាវិមន្តគិតយ៉ាងណា តែក៏មិនចង់ធ្វើអ្វីនៅពេលនេះ នាងគ្រាន់តែចង់ក្លាយជាស្ត្រីជោគជ័យ ដាក់ទូរសព្ទចុះនាងបន្តធ្វើការដូចធម្មតា។ អាណិតតែកំលោះវិមន្តប្រាប់គេថាងងុយតែខ្លួននៅតែដើរចុះឡើងក្រោមតំណក់សន្សើម គិតយ៉ាងណាបើមនុស្សដែលខ្លួនស្រលាញ់មិនជំទាស់ក្តីស្រលាញ់ តែក៏មិនទទួលស្នេហា។ ពិតជាមិនអាចយល់ពីចិត្តវីរិយ៉ា ម្តងម្កាលនឹកដល់វីណាដែលតែងតែចំណាយពេលឱ្យខ្លួន ហើយក៏កាន់តែគួរឱ្យស្រលាញ់ពីមួយថ្ងៃទៅមួយ

ថ្ងៃ ពេលខ្លះធ្វើឱ្យវិមន្តក៏ចែកចិត្តមិនដាច់ ដូចពាក្យថាស្នេហ៍មិនឈ្នះសិទ្ធ។



នេះមែនទេជាសុភមង្គល? ចុះក្តីបំណងរបស់ខ្ញុំមិនមែនជាសុភមង្គលទេឬ?
ជីវិតរបស់ខ្ញុំមានតែមួយទេ បើខ្ញុំដើរខុសគឺខុសរហូតហើយ តែ!
តើរឿងពីរនេះពិតជាត្រូវមានមួយអត់មួយឬយ៉ាងណា?
តើធ្វើយ៉ាងណាទើបបានទាំងពីរ?

វគ្គ៥

# ទារគេ

ម៉ោងប្រាំបីព្រឹករីណាកំពុងរៀបចំឯកសារ វិមន្តដើរមកដល់មានទាំងសាំងវិចមួយដាក់លើតុជាសញ្ញាថា ផ្ញើម្ចាស់តុ រីណាងើបមើលមុខវិមន្តទាំងញញឹមឌឺះ

- អ្នកណាថាមិនទិញឱ្យគេ?(រីណា)

- ខ្ជិលមើលមុខមនុស្សរអ៊ូយពេលឃ្លានទេ។ (វិមន្តតបបែបឌឺដងសល់ពីយប់)

សត្យាជាម្ចាស់តុជំនួសរីយ៉ាផ្ដែពាក្យឱ្យអ្នកទាំងពីរះ

- ទាំងពីរនាក់ហ្នឹងល្មមគិតគូរហើយ! នៅតែប្រុសមិនស្ដីស្រីមិនស្ដែងនៅហ្នឹងហើយ!

- ស្ដីស្ដែងស្អីគេ? ធ្វើការទៅអ្នកកំលោះសត្យា! បើប្រណែនស្អែកទិញឱ្យខ្ញុំម្ដងទៅ ចាំមើលខ្ញុំប្រកែកឬអត់។ (រីណានិយាយបណ្ដើរលើកសាំងវិចបង្អួតសត្យាបណ្ដើរ)

- មិនហ៊ានទេ។ (សត្យាតបទាំងភ្នែកសម្លឹងទៅរិមន្ត)

រិមន្តដើរមកដល់តុរបស់ខ្លួនឯងឈរមើលទៅសត្យា៖

- សាកម្ដងទៅសត្យា ចាំមើលមានរឿងអ្វីកើតឡើងអត់?

Bryant មកដល់ល្មម ៖

- អ្នកណាមានរឿងអ្វីអ្នកទាំងបី?

សត្យាបែររកជំនួយ៖

- Bryantមកដល់ល្អហើយ ជំនាន់ចាស់ចង់ធ្វើបាបជំនាន់ថ្មី។

- ស្អីគេហ្នឹងសត្យា លេងពាក្យម្ល៉េះជំនាន់ចាស់ថ្មីផង! (វីណាហួសចិត្ត)

- បើសត្យាមិនញ៉ោះជំនួយការខ្ញុំទេ ម្ល៉េះមិនមានរឿងអ្វីសោះ។ (Bryant)

- ឃើញទេសូម្បីតែ Bryant ក៏មិននៅខាងខ្ញុំដែរ ក្នុងការិយាល័យនេះខ្ញុំពិតជាគ្មានអ្នកណាសោះ។ (សត្យានិយាយបែបត្អូញត្អែរ)

- បានហើយសត្យាកុំធ្វើខ្លួនកម្សត់ពេក។ (វីណាបែបជម្រេញ)

Bryantហួសចិត្តបានត្រឹមតែសើច ហើយដើរចូលក្នុងបន្ទប់ធ្វើការរបស់គេទៅ។ អ្នកទាំង៤ចាប់ផ្ដើមការងាររៀងខ្លួន បន្តិចយើងឃើញសត្យាចេះតែទៅសួរនាំការងារពីវិមន្ត។ រៀមច្បងយើងក្លាយជាអ្នកមានជំនាញខ្លាំងក្លា ក្នុងផ្នែកទំនាក់ទំនងក្នុងក្រុមហ៊ុនមួយនេះ ការងារជាច្រើនត្រូវ Bryant ផ្ដល់សិទ្ធិធំឱ្យវិមន្តជាអ្នកសម្រេច បុគ្គលិកផ្សេងៗដាក់ការគោរពចំពោះវិមន្តព្រោះពួកគេក៏ដឹងថា វិមន្តនឹងត្រូវជាអ្នកស្នងតំណែងរបស់ Bryant នាពេលឆាប់ៗ។

ចេញពីបន្ទប់បើកទ្វារ Bryant ហៅរកវិមន្ត៖

- វិមន្ត! មកជួបខ្ញុំបន្តិច។ (Bryant)

- Bryant ចាំមួយភ្លែតសិន ខ្ញុំប្រាប់ការងារទៅសត្យាបង្ហើយសិន។ (វិមន្ត)

Bryant មិនឆ្លើយតែងក់ក្បាលទទួលដឹងហើយក៏បិទទ្វារបន្ទប់វិញ វិមន្តងាកមកពន្យល់សត្យាបន្ត ភ្លេចខ្លួនបន្តិចកញ្ញា
រីណាតឿនទៅនាយ៖

- នែ៎ អនាគតលោកប្រធាន! លោកប្រធានបច្ចុប្បន្នកំពុងរង់ចាំណ៎ា។ (រីណា)

- អំ! ភ្លេចឱ្យឈឹង!(វិមន្តបែបភ្ញាក់)

- អ៊ីចឹងវិមន្តទៅជួប Bryant សិនចុះ ចាំបាយហើយចាំប្រាប់ខ្ញុំបន្តទៀត ព្រោះកៀកដល់ម៉ោងបាយល្ងាចដែរ។(សត្យា)

វិមន្តងក់ក្បាលយល់ព្រមនឹងសត្យា នាយទាញសៀវភៅគំរូមួយក្បាលដើរកាត់តុរីណា ហើយទៅដាក់លើតុរបស់នាង។

- អ្នកនាងជំនួយការ! ជួយយកសៀវភៅនេះទៅទុកលើតុខ្ញុំវិញផង។ (នាយញាក់មុខឌឺឱ្យរីណាមួយចាស់ដៃព្រោះចង់សងសឹកពាក្យនាងទើបថាឱ្យនាយអម្បាញ់មិញ)

- រីណាដកដៃពីកំពុងវាយកុំព្យូទ័រមកលើកសៀវភៅនោះឡើង ធ្វើមុខភាំងដោយភ្ញាក់។

សែនភ្ញាក់នឹងកាយវិការរបស់វិមន្ត នាងតាមសម្លក់រហូតនាយដើរដល់បន្ទប់ Bryant។ សត្យាមិនមាត់គ្រាន់តែតាមមើលកាយវិការអ្នកទាំងពីរហើយលួចសើចតិចៗ រីណាដឹងខ្លួនលួចអៀនបន្តិច នាងធ្វូលក្រដាសគប់ទៅសត្យាចំស្មា៖

- អ៊ូយ! រីណា យ៉ាងម៉េចហ្នឹង?

- សើចអី? ហ្នឹងហើយទុកជាការព្រមាន! (នាងញាក់មុខឌឺ)

សត្យាអង្អែលស្មាតិចៗ រើសក្រដាសដាក់ក្នុងធុងសំរាម។ (នាយឌី) មកពីអ៊ីចឹងបានគេមិនហ៊ាន!

- មិនហ៊ានអី?

- មិនហ៊ានសុំស្រលាញ់ ព្រោះវីណាកាចពេក។

- អ្នកណា? សត្យាឯងហ្នឹងហ្ន៎?

- ទេ ទេ! មិនមែនខ្ញុំទេ! ដឹងខ្លួនឯងហើយនៅធ្វើពើទៀត។

- បានសម្ដីណាស់យើងហ្នឹង! តិចត្រូវទៀតឥឡូវហើយ។ (វីណាអៀនតិចៗ រៀបចេញពីតុទៅវ៉ៃសត្យា)

- នែ៎ៗ! តិចៗទៅ! អ្នកនាងជំនួយការ លោកប្រធានទាំងពីរកំពុងប្រជុំណា!

វីណាឈរទ្រឹងពាក់កណ្ដាលផ្លូវ សម្លក់សត្យាទាំងញញឹមបន្តិចនាងដើរត្រឡប់មកតុរបស់ខ្លួនវិញ។

- ផ្ញើទុកសិនចុះសត្យា!

អ្នកទាំងពីរងាកមកបន្តការងាររៀងខ្លួនវិញ។

នៅក្នុងបន្ទប់ Bryant និងវិមន្ត កំពុងតែពិភាក្សាគ្នា៖

- Bryant ដូចជាឆាប់ពេកហើយ ខ្ញុំដូចជាមិនទាន់ត្រៀមខ្លួនស្រួលបួលទេ។

- មិនយូរហើយក៏មិនធាប់ដៃរណារិមន្ត ៣ខែហ្នឹងគឺល្មមហើយ។

- ខ្ញុំដូចជាយ៉ាងម៉េចទេនេះ Bryant សុំពន្យារកុងត្រាកន្លះឆ្នាំសិនទៅបានទេ?

- ហាសហា! រិមន្ត! ម៉េចក៏មិនដូចជានាងតូចខ្ញុំសោះ ធ្វើឱ្យខ្ញុំនឹករីវីយ៉ាខ្លាំងណាស់។

- ខ្ញុំចិត្តមិនខ្លាំងដូចជានាងតូចរីវីយ៉ាទេ មិនអាចប្រៀបធៀបនាងបានទេ។

- តែរិមន្តក៏មិនអន់ដែរ អ្នកទាំងពីរមានចំណុចខ្លាំងរៀងខ្លួន។ នែ៎! នេះខ្ញុំបង្ហាញតារាងការងារខ្ញុំបន្តិច។

រិមន្តជ្រងសក់បែបអស់កម្លាំង៖

- រាល់ថ្ងៃនេះ ការងារខ្ញុំប៉ុណ្ណឹងរវល់ណាស់ទៅហើយ ងាកមកមើលតារាងការងាររបស់ Bryant ច្រើនជាងខ្ញុំមិនតិចដង ខ្ញុំត្រូវបែងចែកជាខ្លួនប៉ុន្មានទៅ?

- យី រិមន្ត! ចុះរាល់ថ្ងៃខ្លួនខ្ញុំមានប៉ុន្មាន?

រិមន្តសើចយកដៃអេះក្បាល Bryant វ៉ែស្មារិមន្តតិចៗដោយមុខម៉ឺងម៉ាត់។

- ជំនួយការខ្ញុំ ក៏ខ្ញុំផ្ទេរឱ្យដែរ!

វិមន្តផ្ទុះសំណើចកាន់តែខ្លាំងៈ

- ហាសហាសហា...! មិនដឹងថាអ្នកណានឹងក្លាយជាជំនួយការរបស់អ្នកណាទេ Bryant។

Bryant យល់ន័យ នាយក៏សើចតាមៈ

- អ៊ីចឹងខ្ញុំឱ្យវិមន្តឯងសម្រេចទៅ តែគ្រាន់តែចង់បញ្ជាក់ថា

តារាងការងារទាំងនេះ មួយចំនួនគឺវីណាជាអ្នកធ្វើ ខ្ញុំគ្រាន់តែពិនិត្យចុងក្រោយប៉ុណ្ណោះ។

វិមន្តនៅតែសើចមិនឈប់ Bryant គ្រវីក្បាលៈ

- ឈប់នឹកវីរិយ៉ាហើយ?

វិមន្តប្រែមុខស្មើមួយរំពេច។

- ខ្ញុំមិនយល់ពីចិត្តវីរិយ៉ាទេ តែក៏ចែកចិត្តមិនដាច់ពីវីណា។

- គិតឱ្យបានស្រួលបួលណាវិមន្ត! គេទាំងពីរនាក់នេះជាមិត្តល្អនឹងគ្នាណាស់ កុំធ្វើឱ្យមិត្តភាពពួកគេប្រេះស្រាំ ខ្ញុំដល់ពេលចេញទៅក្រៅហើយ នៅមើលការងារទាំងនេះតាមសម្រួលចុះ។

វិមន្តងក់ក្បាលទទួល Bryant ដើរចេញទៅ។ អង្គុយស្ងៀមស្ងាត់មួយស្របក់ វិមន្តទាញសៀវភៅដើរចេញពីបន្ទប់

Bryant ទាំងទឹកមុខស្ងួតស្ងប់។ រីណាលួចមើលទឹកមុខចម្លែកមួយនេះមួយសន្ទុះ នាងដើរទៅចាក់ទឹកត្រជាក់មួយកែវមកៈ

- អនាគតលោកប្រធានញ៉ាំទឹកទៅ។ (រីណា)

- អរគុណអ្នកនាងជំនួយការ។ (វិមន្តទទួលទាំងញញឹម)

- ទឹកនោះផ្អែមដែរទេវិមន្ត ?( សត្យា )

- សត្យាចង់ញ៉ាំដែរមែនទេ ?(រីណា)

- អត់ទេគ្រាន់តែចង់ដឹង ព្រោះមើលទៅដូចជាមានមន្តអ្វីនៅក្នុងទឹកនោះ មុខក្រៀមៗញ៉ាំទៅមុខស្រស់ភ្លាម។ (សត្យា)

វិមន្តមិនស្តីបានតែញញឹម ឯរីណាសម្លក់សត្យាទាំងក្នាញ់ សត្យាកំហូចបានត្រឹមតែញាក់មុខឌឺដាក់នាង។

- តស់ទៅញ៉ាំបាយទៅ។ (វិមន្ត)

- មិនបានចូលរួមទេថ្ងៃនេះមានណាត់ហើយសុំទោសផងហេហេ។ (សត្យា)

- អីយ៉ា! មិននាំមកឱ្យស្គាល់ផងទេឬសត្យា ? (រីណា)

- ហាសហា មិត្តចាស់សោះហ្នឹង ជាពិសេសគេភេទដូចគ្នាទៀត ខ្ញុំមិនមែនបាណាណាទេរីណា។ (សត្យា)

- ហាសហា ឆាប់រកមួយទៅណាសត្យា ប្រយ័ត្នរីណាថាយើងមិនស្រលាញ់មនុស្សស្រីណា៎។ (វិមន្ត)

- ត្រូវហើយ មួយខែក្រោយតែមិនរកម្នាក់មកណែនាំឱ្យពួកយើងស្គាល់ទេ សត្យាឯងនឹងត្រូវប្រើឈ្មោះថ្មីហើយ។ (រីណា)

- យ៉ា! ព្រួតគ្នាហើយទេតើនេះ! មិននៅទេ ទៅហើយ។

សត្យានិយាយចប់ទាញសោឡានរត់ទៅរ៉ុយ រីណាមើលមុខវិមន្តក្នុងក្រសែភ្នែកស្មើះ

- យើងសាក call ទៅវិរិយ៉ាទៅ ក្រែងថ្ងៃនេះគេទំនេរមកញ៉ាំបាយជាមួយយើង?

- ល្អណាស់តើ!

រីណាទាញទូរសព្ទ Call ទៅវិរិយ៉ាភ្លាមៗ

- ជម្រាបសួរបងស្រី! តស់ញ៉ាំបាយ។ (សំឡេងកំហូចរបស់វិរិយ៉ា)

- ចា៎! ជម្រាបសួរអ្នកបងប្រធាន ម៉េចដូចដឹងម្ល៉េះ? ទៅបានមែនឬអី?

- ហេហេ ចិត្តដូចគ្នាណាស់ ថ្ងៃនេះពិតជាចង់ Call រកឯងញ៉ាំបាយមែនណា។

- អូខេល្អហើយ! អ៊ីចឹងតិចទៀតជួបគ្នានៅហាងជប៉ុនមួយនោះទៅ។

- ចាំ! ដឹងហើយ បន្តិចទៀតជួបគ្នាណា ខ្ញុំនៅក្នុងឡាន ស្រាប់ហើយ ហេហេ។

- ល្អម្ល៉េះទេថ្ងៃនេះហ្ន៎! អូខេជួបគ្នាបន្តិចទៀតណា។

និយាយចប់ងាកទៅប្រាប់វិមន្តះ

- ថ្ងៃនេះយើងទាំងពីរធ្វើបុណ្យដល់ហើយ។

- អ្នកនាងប្រធានគេទំនេរ?

- ហ្នឹងហើយ តស់ឆាប់ទៅព្រោះគេកំពុងបើកឡានទៅ ស្រាប់។

- ខ្ញុំមានរឿងខ្លះត្រូវពិភាក្សានឹងវីណាទៀត យើងនិយាយ ក្នុងឡានទៅ។

- ចាំ លោកប្រធាន! (វីណាបង្ហាញមុខខឹ)

ក្នាញ់ពេកស្ទើរតែចាប់ថើបទៅហើយ វិមន្តយកដៃអង្អែល ក្បាលអ្នកនាងជំនួយការ គេសើចស្នាញដាក់គ្នាដើរទៅឡា ន។ ក្នុងឡានមានចម្រៀងកំដរ តែវិមន្តនៅតែតប់ប្រមល់។ នាយរអ៊ូទៅវីណាះ

- វីណា ខ្ញុំពិបាកធ្វើចិត្តណាស់ពេលដឹងថា Brayant គាត់ជិតនឹងចេញទៅ។

- វិមន្តខ្វល់ពីការងារដែលត្រូវប្រឈមឬក៏មនោសញ្ចេតនា?

- ទាំងពីរហ្នឹង! មានអារម្មណ៍ហេងហាងដល់ហើយ ពិបាកពីមុនធ្លាប់តែសួរគាត់ ចុះបើគាត់អត់នៅឱ្យសួរអ្នកណា?

- យី វិមន្តនេះ! ដូចជាទន់ជ្រាយដល់ហើយ។

- ខ្ញុំមិនពូកែដូចអ្នករាល់គ្នាគិតទេ រីណាកុំធ្វើជាអ្នកដទៃមើលឃើញភាពទន់ជ្រាយរបស់ខ្ញុំផង។

រីណាស្រាប់តែមានអារម្មណ៍យល់ចិត្តអ្នកកំលោះ នាងងាក

ទៅសម្លឹងគេដោយក្រសែភ្នែកចម្លែក។ ឡានបង្អន់ល្បឿនជាសញ្ញាថាដល់កន្លែងចូលចត នាងភ្ញាក់បន្តិចរៀបចំខ្លួនចុះពីឡាន កំលោះវិមន្តមិនបានចាប់អារម្មណ៍ការយកចិត្តទុកដាក់មួយនោះសោះ រួសរាន់ចេញទៅឆាប់បានជួបមុខរីយ៉ា។ ទាំងពីរនាក់ដើរចូលទៅក្នុងហាងឃើញនាងតូចរីយ៉ាអង្គុយទល់មុខកុំព្យូទ័រ ដូចកំពុងនៅក្នុងការិយាល័យ គេមើលមុខគ្នាជ្រួញចិញ្ចើម រីណាគ្រវីក្បាលដើរចូលទៅជិតៈ

- នែ៎អ្នកនាង! មកញុំាបាយឬមកធ្វើការ? (រីណា)

វីរិយ៉ាសើចស្ងាញដាក់សម្លាញ់ទាំងពីរះ

- មកទាំងពីរបានទេ អ្នកមីង?

វិមន្តទប់សំណើចមិនបាននឹងមុខក្រមិចក្រមើមរបស់វីរិយ៉ា ជាមួយពាក្យក្លែមទៅរីណា នាយផ្ទុះសំណើចមួយទំហឹង។ រីណាសែនក្នាញ់នាយ នាងញ៉ឹងត្រចៀកនាយ។

- នែ! សើចអី? សប្បាយចិត្តបើខ្ញុំចាស់យ៉ាងនេះឬ? (រីណា)

- អត់ទេ! អត់សើចរីណាទេ លែង! លែង! អ្នកណាទៅហ៊ានសើចព្រះនាងម្ចាស់រីណាទៅ លែងទូលបង្គំទៅទាន។ (វិមន្តអង្វរនិងចាប់ដៃរីណាឱ្យលែងនាង)

ឃើញភាពស្និទ្ធស្នាលរបស់គេទាំងពីរ វីរីយ៉ាប្រែទឹកមុខទៅជាងឿងឆ្ងល់និងអន់ចិត្ត លើកកែវតែក្រេបបន្តិចបន្លប់ការចាប់អារម្មណ៍ះ

- នែ៎ទាំងពីរនាក់! ខ្ញុំ Order ម្ហូបរួចហើយ ចាំតែញ៉ាំទៅ។ (វីរិយ៉ា)

- Ok! ស្រួលហើយមិនចាំបាច់គិតច្រើន។ (វិមន្ត)

- គិតច្រើនស្អីទេ បើលើកណាក៏ញ៉ាំតែមុខដដែលៗ ហ្នឹង។ (រីណា)

- ចុះបើរីណាចូលចិត្តតែប៉ុន្មានមុខហ្នឹងដែរហ្នឹង។ (វិមន្ត)

- ចុះអាចហៅមុខដែលវិមន្តចូលចិត្តបានដែរតើ មានឱ្យញ៉ាំតាមគេឯណា។ (រីណា)

- ផ្ដាប់ចិត្តហើយខុសទៀត។ (វិមន្តធ្វើមុខកម្សត់)

តែអ្នកដែលកម្សត់គឺជាកញ្ញាវិរិយ៉ាទៅវិញទេ នាងដាក់ភ្នែកទៅកុំព្យូទ័រតែត្រចៀកចាំស្ដាប់ពាក្យផ្ដោះផ្ដងរបស់មិត្តទាំងពីរ លួចគិតម្នាក់ឯង "តើពួកគេដើរដល់ផ្លូវណាហើយ? វិមន្តយ៉ាងម៉េចហ្នឹង? និយាយទូរសព្ទជាមួយគ្នាមិនអ៊ីចឹងទេ តែពេលជួបមិនដូចអ្វីដែលគិតសោះ" ស្លុងនឹងការគិតនាងហាក់មិនឮសំឡេងដែលកំពុងហៅ៖

- វីរិយ៉ា! វីរិយ៉ា! (វិមន្ត)

រីណាអង្រួនដៃដាស់វីរិយ៉ាពីការភ្លឹកស្មារតីរបស់នាង។

- ឯងគិតដល់ណាហើយ? ម៉េចក៏គ្មានវិញ្ញាណសោះអ៊ីចឹង?

- ហ្អ៎! សុំទោស ការងាររវល់ពេក ត្រូវឱ្យគិតច្រើនណាស់ណ៎ារីណា។ (វីរិយ៉ា)

- ផ្អាកការងារសិនទៅបានទេអ្នកនាង? ដល់ម៉ោងញ៉ាំបាយហើយណា។ (វិមន្ត)

- ទុកកុំព្យូទ័រមួយដុំសិនទៅ ទើសកន្លែងដាក់ម្ហូបណាអ្នកនាង។ (រីណា)

វីរិយ៉ាធ្មឹងៗធ្វើតាមបង្គាប់រីណាប្រាប់ វិមន្តចេះតែលួចសម្លឹងមើលកាយវិការភ្លឹករបស់នាង។ ម្ហូបរៀបដាក់ពេញតុអ្នកទាំងបីអង្គុយញ៉ាំយ៉ាងស្ងៀមស្ងាត់ វិមន្តចាប់ម្ហូបដាក់ឱ្យវីរិយ៉ា នាងងើបមុខសម្លឹងទៅនាយដោយគ្មានស្នាមញញឹម និងពាក្យអរគុណ ពេលខ្លះរីណាដណ្តើមម្ហូបនៅជាប់ចង្កឹះរបស់វិមន្ត ម្តងៗឃើញពួកគេទង្គិចចង្កឹះគ្នាក្នុងចានម្ហូប វីរិយ៉ាចេះតែលួចចាប់អារម្មណ៍ភាពស្និទ្ធស្នាលរបស់មិត្តនាង អាហារមួយពេលនេះដូចជាគ្មានរសជាតិសម្រាប់វីរិយ៉ាសោះ។ ម្តងៗ វិមន្តចេះតែលួចមើលទឹកមុខប្លែកៗរបស់វីរិយ៉ាដូចគ្នា នាយដូចមិនដឹងខ្លួនថា វីរិយ៉ាកំពុងគិតអ្វីនោះទេ។

- វីរិយ៉ាដូចជាមិនសប្បាយចិត្ត? (វិមន្ត)

- គ្មានអ្វីក្រៅតែពីការងារទេ។ (រីណា)

- មែនហើយ! ជាទម្លាប់ទៅហើយ។ (វីរិយ៉ា)

- ហេតុអ្វីចាំបាច់ធ្វើបាបខ្លួនយ៉ាងនេះវីរិយ៉ា? (វិមន្ត)

- ធ្វើបាបខ្លួនអី! វីរិយ៉ារីករាយនឹងជីវិតបែបនេះទៅវិញទេ កាន់តែពិបាក កាន់តែមានសង្ឃឹម។ (រីណា)

- ត្រូវហើយ ព្រោះខ្ញុំនឹងជិតដល់ក្តីប្រាថ្នារបស់ខ្ញុំហើយ ចុះឯងវិញវីណាបានទៅដល់ក្តីប្រាថ្នាឬនៅ? (វីរិយ៉ា)

- ទៅដល់ក្តីប្រាថ្នា? យី ខ្ញុំដូចជាមិនយល់សំណួរឯងទេ។ (វីណាបែបឆ្ងល់)

- ចុះឯងបន់ស្រន់សុំទេពច្បុតកាលនៅសមុទ្រនោះ? (វីរិយ៉ា)

- អ៎! វាជារឿងអនាគតទេណា ពេលនេះមិនទាន់ដល់ពេលនោះទេ។ (វីណា)

- យ៉ាងហោចណាស់ក៏មានចំណុចចាប់ផ្តើមបន្តិចបន្តួចពីពេលនេះទម្រាំដល់ពេលនោះ។ (វីរិយ៉ាបែបបញ្ឆិតបញ្ឆៀងរកការពិត)

- ល្អដូចវីណា ជាមួយនឹងបំណងប្រាថ្នាសាមញ្ញបែបនេះគង់តែដូចចិត្តទេ។ (វិមន្ត)

វីណាងាកទៅមើលមុខវិមន្ត នាងសម្លឹងក្នុងក្រសៃភ្នែកមានសង្ឃឹម វីរិយ៉ាកាន់តែមានការសង្ស័យ។

- ចុះវិមន្តវិញ? នៅមិនទាន់ប្រាប់ទេណាថាប្រាថ្នាអ្វី! (វីណា)

- យី! នៅតាមសួរទៀត ហេហេ មិនប្រាប់ទេ! (វិមន្ត)

វីរិយ៉ាលែងស្តីឱនញ៉ាំបាយបន្ត វិមន្តតាមមើលទឹកមុខនិងកាយវិការរបស់វីរិយ៉ាជាប់រហូត តែនៅតែមិនយល់ពីនាង។ វីណាផ្តើមសន្ទនាបន្តះ

- នែ់វីរិយ៉ា! Bryant ជិតត្រឡប់ទៅបារាំងវិញហើយណា។ (វីណា)

- ហ៎!ឆាប់ណាស់! (វីរិយ៉ាភ្ញាក់ផ្អើល)

- មែនហើយ! ខ្ញុំដូចជាមិនស្រួលក្នុងចិត្តទេវីរិយ៉ា។ (វិមន្តចាប់ផ្តើមត្អូញត្អែរ)

- ទៀតហើយវិមន្ត។ (វីណា)

- ការងារទាំងប៉ុន្មានរបស់គាត់ត្រូវធ្លាក់លើខ្ញុំណា។ (វិមន្ត)

- ឡើងតំណែងហើយ មិនសប្បាយចិត្តទេ? (វីរិយ៉ា)

- ខ្ញុំត្រូវរ៉ាប់រងសម្ពាធជាច្រើន ហើយក៏មានអារម្មណ៍ថាបាត់បង់បងប្រុសម្នាក់។ (វិមន្ត)

- សួរអ្នកបងវីរិយ៉ាទៅវិមន្ត ឱកាសល្អហើយ នែ់! គេធ្វើយ៉ាងម៉េចខ្លះពីដំបូង។ (វីណា)

- មែនហើយពីរបីខែដំបូងពិបាកណាស់ ដូចជាថៃវទូកម្នាក់ឯងកណ្តាលទន្លេ ទោះជាហត់យ៉ាងណាក៏មិនអាចឈប់

ទោះជាភ្លៀងខ្យល់យ៉ាងណាក៏មិនត្រូវសម្តែងការខ្លាច រស់នៅលាក់អារម្មណ៍ពិត លាក់ភាពទន់ខ្សោយដែលមាន។ (វីរិយ៉ានិយាយទាំងសំឡេងឯកា)

វិមន្តស្តាប់ហើយអាណិតវីរិយ៉ាជាពន់ពេកៈ

- ហត់ណាស់សម្រាកខ្លះទៅវីរិយ៉ា។

- អត់ទេ ខ្ញុំដើរបានពាក់កណ្តាលផ្លូវហើយ ខ្ញុំមិនបកក្រោយដាច់ខាត។ (វីរិយ៉ាតបទាំងមុខម៉ឺងម៉ាត់)

វីណាសម្លឹងមុខវីរិយ៉ាគ្រវីក្បាលដោយយល់ពីមហិច្ឆតារបស់មិត្តៈ

- ពេលណាទៅទើបឯងចង់សម្រាក? (វីណា)

- សម្រាកយ៉ាងម៉េច បើមិនទាន់ឈានជើងដល់កន្លែងដែលចង់ទៅផង។ (វីរិយ៉ា)

- តើនេះឬជាសុភមង្គលដ៏ពិតប្រាកដរបស់ឯង? (វីណា)

- ហ្នឹងហើយ! (វីរិយ៉ា)

- សុភមង្គលរបស់មនុស្សស្រីភាគច្រើន គឺក្រុមគ្រួសារតូចមួយជាមួយមនុស្សដែលគេស្រលាញ់ តែវីរិយ៉ាមិនមែននៅក្នុងចំណោមទាំងនោះទេ ណាំវីណា។ (វិមន្ត)

- ស្នេហាក៏ជាសុភមង្គលមួយដែរ តែវាមិនមែនជាក្តីស្រមៃរបស់ខ្ញុំនៅពេលនេះទេ សាងសុភមង្គលក្នុងរឿងស្នេហាគឺត្រូវការឱ្យមនុស្សម្នាក់ទៀតមកធ្វើវាជាមួយយើង តែបើគេមិនមានការតាំងចិត្តមុតមាំ យើងម្នាក់ឯងទោះខំយ៉ាងណាក៏មិនជោគជ័យដែរ បើអស់សង្ឃឹមហើយ វាធ្វើឱ្យមនុស្សហត់ណាស់ ខ្ញុំចង់ធ្វើអ្វីដែលខ្ញុំអាចធ្វើដោយម្នាក់ឯងបានសិន គឺបំណងប្រាថ្នាមួយនេះហើយ នៅថ្ងៃមួយដែលខ្ញុំសម្រេចបានជោគជ័យហើយខ្ញុំប្រហែលជាស្កប់ស្កល់។ (វីរិយ៉ា)

- ចុះបើឯងត្រូវចំណាយពេល១០ឆ្នាំទៀតដើម្បីបំណងប្រាថ្នាមួយនេះ តើមានមនុស្សប្រុសឯណាគេចាប់អារម្មណ៍យាយចាស់ទៀតទៅ? (វីណា)

- ខ្ញុំនឹងស្កប់ស្កល់នឹងជោគជ័យមួយនេះ ទោះជាខ្ញុំមិនមានមនុស្សសំខាន់ក្បែរខ្លួន។ (វីរិយ៉ា)

- មនុស្សប្រុសធម្មតាម្នាក់ គេនឹងមិនហ៊ាននៅក្បែរវីរិយ៉ានោះទេ នៅថ្ងៃមួយដែលវីរិយ៉ាជោគជ័យបំផុត។ (វិមន្ត)

- ហេតុអ្វីក៏គេមិនខំឱ្យជោគជ័យដូចខ្ញុំដែរទៅ? (វីរិយ៉ា)

- គេស្រលាញ់ឯងមិនមែនត្រូវតែធ្វើដូចឯងទេវីរិយ៉ា។ (វីណា)

- មនុស្សមានក្តីប្រាថ្នារៀងខ្លួនណាវីរិយ៉ា។ (វិមន្ត)

- អ៊ីចឹងខ្ញុំនៅតែទៅរកក្តីប្រាថ្នារបស់ខ្ញុំ។ (វីរិយ៉ា)

វីរិយ៉ាឆ្លើយទាំងអន់ចិត្តទម្លាក់ស្លាបព្រាចុះ ទាញកែវតែមកក្រេប វីណាសម្លឹងមុខដែលស្រពោនរបស់មិត្តនាង វិមន្តដកដង្ហើមធំនឹងគំនិតផ្ទុយគ្នារវាងខ្លួន និងម្ចាស់បេះដូងរបស់នាយ វីរិយ៉ាងាកទៅហៅបុគ្គលិកក្នុងហាងឱ្យគិតលុយដើម្បីចេញពីការសន្ទនាដែលមិនយល់ចិត្តគ្នានេះ៖

- ឯងយ៉ាងម៉េចហ្នឹងវីរិយ៉ា? ដូចជាខឹងនឹងពួកយើង? (វីណា)

- អត់ទេ! គ្រាន់តែគំនិតមិនដូចគ្នាមិនមានអ្វីជាបញ្ហាទេ ខ្ញុំដឹងថាអ្នកទាំងពីរចង់ឱ្យខ្ញុំល្អ។ (វីរិយ៉ា)

- មិនគិតពីរឿងស្នេហាមិនមែនជាកំហុសទេ។ (វីណា)

- តែបើបិទផ្លូវមនោសញ្ចេតនាវាដូចជាធ្វើបាបខ្លួនឯង។ (វិមន្ត)

- ស្នេហាគ្រាន់តែជារនាំងឈានទៅរកភាពជោគជ័យរបស់ខ្ញុំតែប៉ុណ្ណោះ បើមានមនុស្សម្នាក់ស្រលាញ់ខ្ញុំដោយពិតប្រាកដ គេគួរជាមនុស្សដែលតែងតែគាំទ្រខ្ញុំ អាចរង់ចាំខ្ញុំបាន។ (វីរិយ៉ានិយាយទាំងជ្រួញចិញ្ចើមដាក់វិមន្ត)

- ព្រោះវីរិយ៉ាមិនអាចរស់នៅដូចមនុស្សស្រីធម្មតាបានទេ។ (វីណាបែរមកនៅខាងវីរិយ៉ាបន្ថយការតានតឹងរបស់នាង)

- មែនហើយ! វីរិយ៉ានឹងក្លាយជាមនុស្សស្រីអស្ចារ្យម្នាក់ ខ្ញុំមានមោទនភាពចំពោះវីរិយ៉ាណាស់ តស៊ូទៀតទៅ។ (វិមន្ត បង្អប់ន័យ)

វីរិយ៉ាងើបចេញពីតុទាំងសម្លក់ បន្ទាប់ពីវិមន្តបង់ថ្លៃអាហារ វីណាចម្លែកនឹងទង្វើនេះ នាងស្ទុះយ៉ាងលឿនទៅតាមវីរិយ៉ា៖

- ឯងយ៉ាងម៉េចហើយវីរិយ៉ា កុំខឹងខ្លាំងពេកពួកយើងគាំទ្រឯងណា។ (វីណា)

- ឯងទើបគាំទ្រខ្ញុំ តែមនុស្សមួយចំនួនគេមិនទេ។ (វីរិយ៉ា)

វីរិយ៉ាតបស្របពេលវិមន្តដើរមកតាមក្រោយងាកទៅសម្លក់ម្តងទៀតក៏ចូលឡានបើកទៅបាត់។ វីណាមើលមុខវិមន្តទាំងស្រឡាំងកាំង វិមន្តមិនតបតអ្វីគ្រាន់តែបើកទ្វារឡានឱ្យនាង ក្នុងឡានអ្នកទាំងពីរលែងមានការឆ្លងឆ្លើយអ្វីទាំងអស់។

ចំណែកអ្នកនាងវិរិយ៉ាមុខក្រម៉ូវ បើកឡានដូចហោះមកដល់ការិយាល័យ ម្នាក់ៗគ្រាន់តែឃើញមុខបងស្រីប្រធានហើយឱនមុខជ្រប់ចុះលែងហ៊ានសួរនាំរឿងអ្វី។

បញ្ញាវន្តដើរកាត់បន្ទប់ធុងកាហ្វេឮបុគ្គលិកឈរនិយាយគ្នាពីទឹកមុខខឹងរបស់វិរិយ៉ាថ្ងៃនេះ នាយបញ្ញាឱ្យបុគ្គលិកម្នាក់ធុងកាហ្វេទឹកកកមួយកែវឱ្យ។

សំឡេងគោះទ្វារយ៉ាងសុភាពនៅមុខបន្ទប់បងស្រីប្រធាន ៖

- ចូលមក!

- កាហ្វេទឹកកកមកដល់ហើយបងស្រីប្រធាន។

វិរិយ៉ាប្រែទឹកមុខបន្តិច ៖

- បងចិត្តបានម្ល៉េះ?

- រាល់ដងបងចិត្តមិនបានចំពោះវិរិយ៉ាទេ?

- មិនមែនទេ! តែនែ៎ ខ្ញុំមិនចង់ញ៉ាំកាហ្វេទឹកកកអ៊ីចឹងទេ។

- បងដឹងថាវិរិយ៉ាទម្លាប់ញ៉ាំកាហ្វេក្តៅក្រោយអាហារថ្ងៃត្រង់។

- ចុះម៉េចក៏យកកាហ្វេទឹកកកឱ្យខ្ញុំ?

- ខ្លាចវិរិយ៉ាកាន់តែក្តៅហ្នឹងណា៎។

វីរិយ៉ាប្រែមុខង៉ក់ងរលែងស្ដី បញ្ឈរន្ដអង្អែលក្បាលរួចដក សូកូឡាមួយដុំតូចពីក្នុងហោប៉ៅមកឱ្យនាង។

- ស្អីគេហ្នឹងបង?

- ស្ករសូកូឡាហ្នឹងហើយ។

- មានន័យថាម៉េច? ម៉េចក៏សុខៗឱ្យខ្ញុំ? ដូចយ៉ាងម៉េច មិនដឹងទេ។

- វីរិយ៉ាជាបងស្រីប្រធានក្នុងក្រសែភ្នែកមនុស្សនៅទីនេះ ជាមនុស្សមានធន្ធៈរឹងមាំក្នុងក្រសែភ្នែកមនុស្សដែល អូនស្គាល់ តែក្នុងក្រសែភ្នែកបង វីរិយ៉ាគ្រាន់តែជាកូន ក្មេងដែលមានះម្នាក់ប៉ុណ្ណោះ។ ក្មេងៗតែងត្រូវបានស្ករសូកូ ឡាលួងឱ្យសប្បាយចិត្តវិញ។ បងលួងអូនព្រោះបងគាំ ទ្រភាពមានះ

របស់អូន។ បងយល់ថាយ៉ាងណាក៏ភាពមានះមួយនេះវាជា ការត្រឹមត្រូវ។ អ្នកដទៃអាចមើលឃើញវីរិយ៉ាជាមនុស្សដែល មានមហិច្ឆតាធំជ្រុល តែសម្រាប់បងវិញ បងកោតសរសើរនូវ ការឈ្នុសឈ្នុលរកបំណងប្រាថ្នារបស់ខ្លួនឯងដូចប្អូន។ អ្នក ដទៃក៏តែងមានបំណងប្រាថ្នា តែពួកគេមិនស៊ូនោះទេ គ្រាន់ តែប្រាថ្នាហើយដេកចាំទេវតាប្រទាន តែអូនវិញពិសេសខុស

ពីគេ។ អ្នកណាគិតអ្វីស្រេចតែគេ គ្រាន់តែដឹងត្រឹមថាអូនមានបងដែលគាំទ្រអូន។

ពាក្យប៉ុន្មានម៉ាត់របស់បញ្ញវន្តធ្វើឱ្យវិរិយ៉ាជ្រុះអស់នូវកំហឹង ក្រេបកាហ្វេត្រជាក់បន្តិច បញ្ញវន្តអង្អែលក្បាលនាងហើយបន្ត៖

- កូនក្មេងល្ងង់! ហេតុអ្វីបានខឹងខ្លាំង? ក្រែងទើបមកពីញ៉ាំបាយជាមួយមិត្តល្អ?

- និយាយមិនត្រូវគ្នា គេដូចជាចេះតែចង់ឱ្យខ្ញុំបញ្ឈប់ជំហានដែលខ្ញុំកំពុងដើរ ខ្ញុំមិនយល់ទេ!

- ប្រហែលគេខ្លាចវិរិយ៉ាដើរមិនដល់ ហើយខូចចិត្តខ្លាំង។

- អត់ទេ! ខ្ញុំត្រូវប្រើពេលមួយជីវិតសម្រេចវាឱ្យបាន។

- បើសុទ្ធតែមួយជីវិតយ៉ាងនេះ អ្នកណាមិនបារម្ភទៅ? តិចក្លាយជាយាយចាស់គ្មានគ្រួសារដោយសារតែមហិច្ឆតាមួយនេះ។ (បញ្ញវន្តញ៉ោះ)

- ម្នាក់ទៀតហើយ! (វិរិយ៉ាប្រែមុខងរង៉េក់)

- តែបងជឿវិរិយ៉ានឹងជោគជ័យ ហើយនឹងមិនក្លាយជាយាយចាស់ឯកោដាច់ខាត។

បញ្ញាវន្តទះស្មានាងតិចៗបង្ហាញភាពជឿជាក់ នាងញញឹមបន្តិចលើកកាហ្វេក្រេបបន្ថែម៖

- អរគុណបងដែលតែងតែនៅខាងខ្ញុំ។

- សប្បាយចិត្តវិញគឺល្អហើយ បងមានប្រជុំបន្ទាន់ ហើយល្ងាចនេះបងត្រូវឡើងយន្តហោះទៅហុងកុងដើម្បីការប្រជុំថ្ងៃស្អែកទៀត ខានស្អែកទើបមកវិញ។

- ថ្ងៃខានស្អែកខ្ញុំត្រូវទៅប្រជុំនៅបារាំងដែរ។

- មិនបានជួបគ្នាយូរថ្ងៃហើយអ៊ីចឹង។

បញ្ញាវន្តធ្វើមុខជូរ វិរិយ៉ាសើចហើយរុញខ្នងនាយឱ្យចេញពីបន្ទប់ធ្វើការរបស់នាង៖

- ទៅៗក្រែងថាមានប្រជុំបន្ទាន់នោះអី។

បញ្ញាវន្តដើរតាមការរុញរបស់នាងតូច។ ក្រោយបញ្ញាវន្តទៅបាត់ វិរិយ៉ាបានធូរចិត្តបន្តិចក៏ចាប់ផ្តើមការងារបន្ត។ ទម្លាប់សកម្មនឹងការងាររបស់វិរិយ៉ាតែងតែធ្វើឱ្យនាងភ្លេចម៉ោងទៅផ្ទះ កំពុងតែស្មិងស្មាធិ៍នឹងកញ្ចក់កុំព្យូទ័រ មានសារមួយលោតមក៖

- បងស្រីប្រធានល្មមទៅផ្ទះហើយណា៎ កុំសកម្មពេក លោកនាយកមិននៅទេគាត់មិនដឹងថាបងលួចខំខិលទេ។

- យែស! ភ្លេចឱ្យឈឹង អ៊ីចឹងទៅហើយណ៎ា ផ្ដាំអរគុណម្រាមដៃលោកនាយកដែលខំសរសេរសារនេះផង។

- បានសម្ដីណាស់កូនក្មេង បងឡើងយន្តហោះហើយណាមានការអ្វីសំខាន់អាចទាក់ទងបងបាន។

- ចាំបង! រក្សាខ្លួន។

- អូនក៏អ៊ីចឹងដែរ កុំភ្លេចនឹកបងផង។

វីរិយ៉ាអានសាររួចផ្ទុះសំណើច នាងមិនឆ្លើយតបសាររបស់បញ្ញវន្តទៀតទេ បែរមករៀបចំអីវ៉ាន់ទៅផ្ទះ។ ថ្ងៃនេះចរាចរណ៍ដូចជាមិនកកកុញដូចរាល់ដង។ វីរិយ៉ាបើកឡានទាំងអារម្មណ៍ធូរស្រាល ស្ដាប់បទចម្រៀងនៅក្នុងឡានធ្វើឱ្យនាងមានអារម្មណ៍ថាអផ្សុកបន្តិច បើកទៅមុខឃើញហាងការ៉េមនៅខាងស្ដាំដៃល្មមនាងសម្រេចចិត្តចូលទៅលំហែអារម្មណ៍ម្នាក់ឯង។ ក្មេងប្រុសតូចម្នាក់អាយុប្រហែល២ខួបដើរមកពីណាមិនដឹងសំដៅមករកនាង ហុចផ្កាកុលាបមួយទងឱ្យមកវីរិយ៉ា នាងភ្ញាក់ផ្អើលយ៉ាងខ្លាំងមិនទទួលផ្កាតែចាប់ដៃកូនក្មេងនោះដាប់ដោយក្ដីស្រលាញ់៖

- អូនតូចគួរឱ្យស្រលាញ់ម្ល៉េះហ្នឹង? ឯណាម៉ាក់អូន?

សំណួរមិនទាន់ផុតពីមាត់ នាងឃើញមនុស្សស្រីវ័យ

ប្រហែលលើសនាងបីបួនឆ្នាំរត់មកចាប់ដៃក្មេងតូចនោះជាមួយស្នាមញញឹមៈ

- នែ៎កូន កុំរំខានអ្នកមីងណ៎ា។

- អត់រំខានទេ គាត់គួរឱ្យស្រលាញ់ណាស់។ (វីរិយ៉ាតបទាំងរួសរាយទៅម៉ាក់របស់ក្មេងប្រុស)

បុរសមាឌមាំម្នាក់ដើរមកក្បែរឱបស្មាម៉ាក់របស់ក្មេងប្រុសទំនងជាស្វាមីរបស់នាងៈ

- មិត្តរបស់អូនឬ?

- អត់ទេ! កូនយើងហ្នឹងមករំខានប្អូនស្រី។ (នាងតបទៅស្វាមី)

- អ៎! អ៊ីចឹងទេ សុំទោសណាប្អូនស្រី។ (បុរសមាឌមាំនិយាយទៅវីរិយ៉ា)

- មិនថ្វីទេបង។ (វីរិយ៉ាញញឹមគួរសមទៅអ្នកទាំងពីរ)

- អ៊ីចឹងពួកបងសុំទៅវិញហើយមិនរំខានប្អូនទៀតទេណ៎ា។ (ម៉ាក់របស់ក្មេងតូច)

- Bye bye អ្នកមីងណាកូន! (ប៉ារបស់ក្មេងតូច)

វីរិយ៉ាញញឹមលើកដៃ bye bye ទៅក្មេងតូច។ នាងតាមសម្លឹងមើលគ្រួសារមួយនោះ នឹកដល់សម្តីរបស់មិត្តទាំងពីរ

កាលពីថ្ងៃ។

គិតម្នាក់ឯង៖

“នេះមែនទេជាសុភមង្គល? ចុះក្ដីបំណងរបស់ខ្ញុំមិនមែនជាសុភមង្គលទេឬ? ជីវិតរបស់ខ្ញុំមានតែមួយទេ បើខ្ញុំដើរខុសគឺខុសរហូតហើយ តែ! តើរឿងពីរនេះពិតជាត្រូវមានមួយអត់មួយឬយ៉ាងណា? តើធ្វើយ៉ាងណាទើបបានទាំងពីរ? ប៉ុន្តែវិមន្ត...”

គិតដល់ភាពស្និទ្ធស្នាលរបស់មិត្តទាំងពីរធ្វើឱ្យនាងអស់អ្វីនឹងគិតបន្តទៀត។ ហត់នឿយនឹងគិត វិរិយ៉ាចេញពីហាង

ការ៉េម បើកឡានចុះឡើងពេញក្រុងរហូតដល់យប់

ងងឹត

នាងចូលទៅក្នុងបារបារាំងមួយបន្ទាប់ពីហៅស្រាក្រហមមួយកែវ។ វិរិយ៉ាប្រទះឃើញគូស្នេហ៍បរទេសមួយគូដែលកំពុងតែផ្អែមល្ហែមនឹងគ្នា។ នាងមិនដកភ្នែកពីទិដ្ឋភាពមួយនោះសោះ។គូស្នេហ៍មួយគូនោះហាក់ទទួលអារម្មណ៍ពីការសម្លឹងយ៉ាងភ្លេចខ្លួនរបស់វិរិយ៉ា។ ពួកគេសម្លឹងតបមកនាងទាំង

ញញឹម នាងហាក់ទទួលអារម្មណ៍ភ្ញាក់ខ្លួន នាងកាន់កែវស្រាក្រហមដើរតម្រង់ទៅគូស្នេហ៍មួយគូនោះ៖

- ខ្ញុំសុំទោសដែលមើលអ្នកទាំងពីរដល់ភ្លេចខ្លួនបែបនេះ។ (វីរិយ៉ា)

- ខ្ញុំឈ្មោះJuliគាត់ជាមិត្តប្រុសរបស់ខ្ញុំឈ្មោះBen។ (Juli)

- ខ្ញុំឈ្មោះវីរិយ៉ា អរគុណណាស់ដែលមិនប្រកាន់ខ្ញុំ។ (វីរិយ៉ា)

- ស្គាល់គ្នាទៅ ពួកទើបយើងមកលេងប្រទេសកម្ពុជានេះជាលើកទីមួយហើយ។ (Juli)

- ស្វាគមន៍ការមកលេងដែនដីរបស់ខ្ញុំ។ (វីរិយ៉ា)

- សុំទោសណា! ហេតុអ្វីវីរិយ៉ាមើលមកពួកយើងបែបនេះ? តើពួកយើងមិនសមនឹងធ្វើកាយវិការទាំងនេះនៅប្រទេសរបស់អ្នកឬ? (Ben)

- មែនហើយជួយណែនាំផង ព្រោះពួកយើងមិនចង់ធ្វើអ្វីខុសនោះទេ។ (Juli)

- អត់ទេ! មិនជាអ្វីទេ! តាមប្រពៃណីគឺមិនសម តែសម័យនេះហើយ ប្រជាជនស្រុកខ្ញុំក៏ទាន់សម័យដែរ ហេហេហេ។

(វិរិយ៉ាធ្វើឱ្យអ្នកទាំងពីរសើចយ៉ាងរីករាយ នាងបន្ត) ខ្ញុំគ្រាន់តែមិនសូវមានពេលវេលាចេញក្រៅជាលក្ខណៈបែបនេះ ខ្ញុំមិនដែលចាប់អារម្មណ៍ថា ក្រៅពីការងារតើមនុស្សធ្វើអ្វីខ្លះ ខ្ញុំស្រាប់តែមិនយល់ថា តើក្ដីស្រមៃគួរតែជាអ្វីដែលត្រូវតែយកឱ្យ

បានឬទេ? អ្វីទៅជាក្ដីស្រមៃរបស់អ្នកទាំងពីរ?

មិត្តថ្មីមួយគូធ្វើភ្នែកឡិងឡង់នឹងសំណួររបស់វិរិយ៉ា Juli ឆ្លើយៈ

- គោលបំណងរបស់Benគឺធ្វើជាអ្នកជួយគេ គាត់ជាមនុស្សល្អ គាត់ចង់ជួយមនុស្សគ្រប់គ្នាដោយមិនប្រកាន់ជាតិសាសន៍ឡើយ ខ្ញុំពិតជាលង់ស្នេហ៍នឹងទឹកចិត្តល្អរបស់គាត់ណាស់។

និយាយចប់Juliងាកទៅមើលមិត្តប្រុសរបស់គេ Ben ឆ្លើយបន្តៈ

- បំណងប្រាថ្នារបស់Juli គឺចំណាយពេលជាមួយមនុស្សដែលនាងស្រលាញ់ដើរកម្សាន្តជុំវិញពិភពលោក ដូច្នេះពួកយើងកាន់ដៃគ្នាសម្រេចបំណងប្រាថ្នាឱ្យគ្នា ដូចជាពេលនេះអ៊ីចឹង ខ្ញុំកំដរនាងសម្រេចបំណងប្រាថ្នាដោយការ

មកលេងប្រទេសកម្ពុជា ហើយនាងក៏សម្រេចបំណងរបស់ខ្ញុំ ដោយពួកយើងដើរស្រាវជ្រាវតាមតំបន់ក្រីក្រក្នុងប្រទេសនេះ ដើម្បីសុំជំនួយមកឧបត្ថម្ភដល់ពួកគេ។

- ខ្ញុំស្ងប់ស្ងែងអ្នកទាំងពីរណាស់។ (វីរីយ៉ាតបទាំងទះដៃអបអរ)

បន្ទាប់ពីការប្ដូរលេខទូរសព្ទគ្នា ដើម្បីទំនាក់ទំនងពេលក្រោយ នាងក៏លាមិត្តថ្មីត្រឡប់មកផ្ទះវិញ។

ក្នុងបន្ទប់ងងឹតឈឹងវីរីយ៉ាគេងធ្វើមិនឮសាររបស់វិមន្ត នាងរវល់ខ្វល់ខ្វាយនឹងក្ដីប្រាថ្នាពិតប្រាកដរបស់នាង ណាមួយអន់ចិត្តយ៉ាងខ្លាំងរឿងកាលពីថ្ងៃ ត្រឹមតែប៉ុណ្ណោះវីរីយ៉ាកាន់តែរក្សាគម្លាតជាមួយវិមន្ត។